ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ០២ សប្តាហ៍ទី ១ ថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

p

p

មាតិកា

I_ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

០២-០១-២០១២ -ព្រះរាជក្រម នស/រកម/០១១២/០០២ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិព្រៃ ដែលកំពុងរងគ្រោះថ្នាក់ ១០៥

២_ព្រះរាជក្រឹត្យ

២៣-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧកញ៉ា ចំនួន ០២ រូប ១៥៥

២៣-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជូនលោកឧត្តមសេនីយ៍ទោ សម គារា នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ១៥៦

២៣-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និង មន្ត្រីរាជការ ចំនួន ០៣ រូប ១៥៧

២៣-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១១៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកជំទាវ ចំនួន ០២ រូប ១៥៨

២៦-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១២១ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី ញឹក ស៊ីផន នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ១៥៩

II_រាជរដ្ឋាភិបាល

អនុក្រឹត្យ

៣០-១២-២០១១ -អនុក្រឹត្យលេខ ២៩៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១៦០

២៨-១២-២០១១ -អនុក្រឹត្យលេខ ១៣៤៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៦២

២៨-១២-២០១១ -អនុក្រឹត្យលេខ ១៣៤៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨៣

២៨-១២-២០១១ -អនុក្រឹត្យលេខ ១៣៤៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៩៧

២៨.១២.២០១១ -អនុក្រឹត្យលេខ ១៣៤៦ អនក្រ.បក ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ២០១
២៨.១២.២០១១ -អនុក្រឹត្យលេខ ១៣៤៧ អនក្រ.បក ស្តីពី ការផ្ទេរភារកិច្ច និង តែងតាំងមន្ត្រីរាជការ ២០៣
២៨.១២.២០១១ -អនុក្រឹត្យលេខ ១៣៤៨ អនក្រ.បក ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ២០៥
២៩.១២.២០១១ -អនុក្រឹត្យលេខ ១៣៤៩ អនក្រ.បក ស្តីពី ការតែងតាំងមន្ត្រីរាជការ ២០៦
២៩.១២.២០១១ -អនុក្រឹត្យលេខ ១៣៥០ អនក្រ.បក ស្តីពី ការជូនមេដាយការងារ ២០៧
២៩.១២.២០១១ -អនុក្រឹត្យលេខ ១៣៥១ អនក្រ.បក ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយនគរបាលជាតិជាកិច្ចបច្ឆាមរណៈ ២០៨

III.ការចារបណ្ណាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣០.១២.២០១១-សារាចរណែនាំលេខ ០១៥ សហវ.អពដ ស្តីពី ការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យ ២០៩

ព្រះរាជក្រម

នស/រកម/០១១២/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីពាណិជ្ជកម្ម
អន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិព្រៃ
ដែលកំពុងរងគ្រោះថ្នាក់

មាត្រា ១.-

អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលកំពុងរងគ្រោះថ្នាក់ ដែលបានធ្វើនៅរដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិក នាថ្ងៃទី ០៣ ខែមីនា ឆ្នាំ ១៩៧៣ ហើយរាជរដ្ឋាភិបាលកម្ពុជា បានសុំចូលជាសមាជិកនៃអនុសញ្ញានេះ នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ និងបានក្លាយជាសមាជិកពេញសិទ្ធិទី ១៤០ កាលពីថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២

នស. ១២០១. ០០៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
ច័ន្ទ សារុន

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុសញ្ញា ស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

បានចុះហត្ថលេខានៅរដ្ឋធានីវ៉ាស៊ីនតោន ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៣

បានធ្វើវិសោធនកម្មមាត្រា១១ នៅទីក្រុងបោន ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៧៩

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

p

អត្ថបទអនុសញ្ញា

មាតិកា

មាត្រា ១	និយមន័យ	១
មាត្រា ២	គោលការណ៍ជាមូលដ្ឋាន	៣
មាត្រា ៣	បញ្ញត្តិសម្រាប់ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ I	៤
មាត្រា ៤	បញ្ញត្តិសម្រាប់ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ II	៥
មាត្រា ៥	បញ្ញត្តិសម្រាប់ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ III	៧
មាត្រា ៦	លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ	៨
មាត្រា ៧	អញ្ញត្រកម្ម និងបទប្បញ្ញត្តិពិសេសទាក់ទងនឹងពាណិជ្ជកម្ម	៩
មាត្រា ៨	វិធានការដែលត្រូវប្រកាន់យកដោយភាគីជាសមាជិក	១១
មាត្រា ៩	អាជ្ញាធរគ្រប់គ្រង និងអាជ្ញាធរវិទ្យាសាស្ត្រ	១៣
មាត្រា ១០	ពាណិជ្ជកម្មជាមួយរដ្ឋដែលមិនមែនជាភាគីនៃអនុសញ្ញា	១៤
មាត្រា ១១	សន្និសីទពេញអង្គនៃភាគីជាសមាជិក	១៤
មាត្រា ១២	លេខាធិការដ្ឋាន	១៥
មាត្រា ១៣	វិធានការអន្តរជាតិ	១៦
មាត្រា ១៤	ឥទ្ធិពលទៅលើច្បាប់ក្នុងប្រទេសនិងអនុសញ្ញាអន្តរជាតិ	១៧
មាត្រា ១៥	វិសោធនកម្មឧបសម្ព័ន្ធ I និង II	១៩
មាត្រា ១៦	វិសោធនកម្មឧបសម្ព័ន្ធ III	២១
មាត្រា ១៧	វិសោធនកម្មអនុសញ្ញា	២២
មាត្រា ១៨	ការដោះស្រាយទំនាស់	២៣
មាត្រា ១៩	ការចុះហត្ថលេខា	២៣
មាត្រា ២០	ការផ្តល់សច្ចាបន ការទទួលស្គាល់ ការយល់ព្រម	២៤
មាត្រា ២១	ការសុំចូលជាសមាជិក	២៤
មាត្រា ២២	ការចូលជាធរមាននៃអនុសញ្ញា	២៤
មាត្រា ២៣	ការទទួលយកអនុសញ្ញាដោយមានធ្វើខ ដាក់លក្ខខណ្ឌ	២៤
មាត្រា ២៤	ការសុំលាលែងចេញពីសមាជិកភាព	២៥
មាត្រា ២៥	ការតម្កល់ឯកសារ	២៥

p

បកប្រែក្រៅផ្លូវការ

អនុសញ្ញា ស្តីពី ពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

បានចុះហត្ថលេខានៅរដ្ឋធានីវ៉ាស៊ីនតោន នាថ្ងៃទី ០៣ ខែមីនា ឆ្នាំ ១៩៧៣
បានធ្វើវិសោធនកម្មនៅទីក្រុងបោន នាថ្ងៃទី ២២ ខែមិថុនា ឆ្នាំ១៩៧៩

រដ្ឋហត្ថលេខីទាំងអស់នៃអនុសញ្ញា

- *ដោយទទួលស្គាល់ថាសត្វ និងរុក្ខជាតិព្រៃ តាមសោភណភាព និងប្រភេទប្លែកៗគ្នារបស់វាគឺជាផ្នែកមួយមិនអាចជំនួសបាននៃប្រព័ន្ធធម្មជាតិរបស់ផែនដីដែលត្រូវតែការពារសម្រាប់មនុស្សជំនាន់នេះ និងជំនាន់ក្រោយ*
- *ដោយមានស្មារតីភ្ញាក់រលឹកចំពោះតម្លៃដែលកាន់តែកើនឡើងជានិច្ចយោងតាមទស្សនៈពាក់ព័ន្ធនឹងសោភណភាព វិទ្យាសាស្ត្រ វប្បធម៌ ការកំសាន្ត និងសេដ្ឋកិច្ចរបស់សត្វ និងរុក្ខជាតិព្រៃ*
- *ដោយទទួលស្គាល់ថាប្រជាពលរដ្ឋ និងរដ្ឋ គឺជាអ្នកការពារដ៏ប្រសើរបំផុតនូវសត្វ និងរុក្ខជាតិព្រៃរបស់ខ្លួន*
- *ដោយទទួលស្គាល់ជាបន្ថែមថាកិច្ចសហប្រតិបត្តិការអន្តរជាតិ គឺជាការចាំបាច់ និងសំខាន់បំផុត ដើម្បីការពារនូវប្រភេទខ្លះនៃសត្វ និងរុក្ខជាតិព្រៃ ប្រឆាំងនឹងការធ្វើអាជីវកម្មហួសកម្រិតតាមរយៈការធ្វើពាណិជ្ជកម្មអន្តរជាតិ*
- *ដោយជឿជាក់នូវភាពបន្ទាន់នៃការចាត់វិធានការសមស្របដើម្បីបញ្ចប់បញ្ហានេះ បានព្រមព្រៀងគ្នាដូចខាងក្រោម ៖*

មាត្រា ១
និយមន័យ

សម្រាប់គោលបំណងនៃអនុសញ្ញានេះ លើកលែងតែមានចែងក្នុងបញ្ញត្តិផ្សេង ពាក្យសព្ទខាងក្រោមមានអត្ថន័យដូចតទៅ ៖

ក- " ប្រភេទ " (Species) : សំដៅដល់ប្រភេទ អនុប្រភេទ ឬពពួកសត្វនិងរុក្ខជាតិផ្សេងទៀតដែល

មាននៅក្នុងភូមិសាស្ត្រណាមួយ។

ខ- " សំណាក " (Specimen) : សំដៅដល់ ៖

១- សត្វ ឬរុក្ខជាតិមួយ ដែលនៅរស់ ឬស្លាប់ទៅហើយក៏ដោយ ។

២- ក្នុងករណីជាសត្វ : សម្រាប់ប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ I និង II គឺជាផ្នែកណាមួយ ដែលអាចសម្គាល់បានជាបំណែកកែច្នៃចេញពីផ្នែកនៃប្រភេទសត្វនោះ ។ សម្រាប់ប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ III គឺជាផ្នែកណាមួយដែលអាចសម្គាល់បានជាបំណែកដែលចេញពីផ្នែកដែលបានកំណត់ក្នុងឧបសម្ព័ន្ធ III ពាក់ព័ន្ធនឹងសំណាកទាំងនោះ ។ និង

៣- ក្នុងករណីជារុក្ខជាតិ : សម្រាប់ប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ I គឺជាផ្នែកណាមួយដែលអាចសម្គាល់បាន ឬជាបំណែកចេញពីផ្នែកនៃរុក្ខជាតិនោះ។ សម្រាប់ប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ II និង III គឺជាផ្នែកណាមួយដែលអាចសម្គាល់បាន ឬជាបំណែកចេញពីផ្នែកនៃប្រភេទរុក្ខជាតិ ដែលបានចុះក្នុងឧបសម្ព័ន្ធ II និង III ពាក់ព័ន្ធនឹងសំណាកទាំងនោះ។

គ- " ពាណិជ្ជកម្ម " (Trade) : សំដៅដល់ការនាំចេញ ការនាំចេញបន្ត ការនាំចូល និងការនាំមកពីសមុទ្រ ។

ឃ- " ការនាំចេញបន្ត " (Re-export) : សំដៅដល់ការនាំចេញនូវសំណាកប្រភេទសត្វ និងរុក្ខជាតិព្រៃដែលបាននាំចូលពីពេលមុន ។

ង- " ការនាំមកពីសមុទ្រ " (Introduction from the sea) : សំដៅដល់ការដឹកជញ្ជូនចូលមកក្នុងដែនសីមានៃរដ្ឋមួយនូវសំណាកនៃប្រភេទមួយ ដែលបានយកចេញពីដែនសមុទ្រដែលមិនស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋណាមួយ ។

ច- " អាជ្ញាធរវិទ្យាសាស្ត្រ " (Scientific Authority) : សំដៅដល់អាជ្ញាធរជាតិ ផ្នែកវិទ្យាសាស្ត្រ ដែលបង្កើតឡើងដោយអនុលោមតាមមាត្រា ៩ នៃអនុសញ្ញានេះ ។

ឆ- " អាជ្ញាធរគ្រប់គ្រង " (Management Authority) : សំដៅដល់អាជ្ញាធរជាតិផ្នែកគ្រប់គ្រងដែលបង្កើតឡើងដោយអនុលោមតាមមាត្រា ៩ នៃអនុសញ្ញានេះ ។

ជ- " ភាគី " (Party) : សំដៅដល់រដ្ឋ ដែលបទប្បញ្ញត្តិរបស់អនុសញ្ញានេះ បានចូលជាធរមានរួចហើយ។

មាត្រា ២
គោលការណ៍ជាមូលដ្ឋាន

១- ឧបសម្ព័ន្ធ I ត្រូវរាប់បញ្ចូលគ្រប់ប្រភេទ ដែលបានទទួលរងនូវការគំរាមកំហែងឈានទៅរកការវិនាសផុតពូជ ឬអាចទទួលការប៉ះពាល់ ដោយសារការធ្វើពាណិជ្ជកម្ម ។ ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃទាំងនេះ ត្រូវស្ថិតក្រោមបទប្បញ្ញត្តិយ៉ាងតឹងរ៉ឹងជាពិសេស ដើម្បីកុំឱ្យមានការរងគ្រោះថ្នាក់បន្ថែមទៀត ដល់ការរស់រានមានជីវិតនៅបន្តទៅទៀតរបស់ពួកវា ហើយក៏ត្រូវបានអនុញ្ញាតតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ ។

២- ឧបសម្ព័ន្ធ II រួមមាន ៖

ក- គ្រប់ប្រភេទសត្វ ឬរុក្ខជាតិព្រៃ ដែលទោះបីជាបច្ចុប្បន្នពុំទាន់ទទួលរងនូវការគំរាមកំហែងឈានទៅរកការវិនាសផុតពូជក៏ដោយ ប៉ុន្តែវាអាចនឹងឈានទៅរកការវិនាសផុតពូជនៅពេលអនាគត ប្រសិនបើការធ្វើពាណិជ្ជកម្ម លើសំណាកនៃប្រភេទទាំងនោះមិនបានដាក់ឱ្យស្ថិតនៅក្រោមបញ្ញត្តិយ៉ាងតឹងរ៉ឹង ដើម្បីជៀសវាងពីការប្រើប្រាស់មិនសមស្របជាមួយនឹងការរស់រានមានជីវិតនៅបន្តទៀតរបស់ពួកវា និង

ខ- ប្រភេទផ្សេងទៀតដែលត្រូវដាក់ឱ្យស្ថិតនៅក្រោមបញ្ញត្តិមួយ ដើម្បីកំណត់ថាពាណិជ្ជកម្មលើសំណាកនៃប្រភេទមួយចំនួនដូចមានចែងក្នុងវាក្យខណ្ឌ (ក) នៃកថាខណ្ឌនេះ អាចយកមកដាក់នូវក្រោមការត្រួតពិនិត្យដោយមានប្រសិទ្ធភាព ។

៣- ឧបសម្ព័ន្ធ III ត្រូវរាប់បញ្ចូលនូវគ្រប់ប្រភេទដែលភាគីជាសមាជិកណាមួយវិនិច្ឆ័យឃើញថាត្រូវដាក់ឱ្យស្ថិតនៅក្រោមបញ្ញត្តិនៃដែនសមត្ថកិច្ចរបស់ខ្លួនសម្រាប់គោលបំណងបង្ការទប់ស្កាត់ ឬរឹតបន្តឹងការធ្វើអាជីវកម្មហើយដែលត្រូវការកិច្ចសហប្រតិបត្តិការពីភាគីដទៃទៀត ក្នុងការត្រួតពិនិត្យការធ្វើពាណិជ្ជកម្មប្រភេទនោះ ។

៤- ភាគីទាំងអស់មិនត្រូវចេញការអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មលើបណ្តាសំណាកនៃប្រភេទទាំងឡាយដែលបានចុះក្នុងឧបសម្ព័ន្ធ I, II និង III លើកលែងតែបានការអនុញ្ញាតដែលអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

p

មាត្រា ៣

បញ្ញត្តិសម្រាប់ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ I

១- ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ I ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ ។

២- ការនាំចេញសំណាកនៃប្រភេទមួយដែលកំណត់ក្នុងឧបសម្ព័ន្ធ I ត្រូវទាមទារឲ្យផ្តល់ និងបង្ហាញជាមុននូវលិខិតអនុញ្ញាតឲ្យនាំចេញ ។ លិខិតឲ្យអនុញ្ញាតនាំចេញត្រូវបានផ្តល់ជូនក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌដូចខាងក្រោម ៖

ក- អាជ្ញាធរវិទ្យាសាស្ត្ររបស់រដ្ឋនាំចេញបានផ្តល់យោបល់ថា ការនាំចេញនឹងមិនធ្វើឱ្យខូចខាតដល់ការរស់រានមានជីវិតនៃប្រភេទនោះ បន្តទៅទៀតឡើយ ។

ខ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញយល់ព្រមថា សំណាកមិនត្រូវបានទទួល ឬបានមកដោយផ្ទុយនឹងច្បាប់សម្រាប់ការពារសត្វ និងរុក្ខជាតិទាំងឡាយរបស់រដ្ឋ ។

គ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញយល់ព្រមថា គ្រប់សំណាកនៅរស់នឹងទទួលបានការរៀបចំនិងដឹកជញ្ជូនដែលកាត់បន្ថយហានិភ័យនាំឲ្យបង្ករបួស ធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ និង

ឃ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញទទួលយល់ព្រមថា លិខិតអនុញ្ញាតនាំចូលត្រូវបានផ្តល់ចំពោះសំណាកដែលបានស្នើសុំនោះរួចហើយ ។

៣- ការនាំចូលសំណាកនៃប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ I ត្រូវទាមទារឱ្យផ្តល់ និងបង្ហាញជាមុននូវលិខិតអនុញ្ញាតនាំចូល និងលិខិតអនុញ្ញាតនាំចេញ ឬវិញ្ញាបនបត្រនាំចេញបន្ត ។ លិខិតអនុញ្ញាតនាំចូលនឹងត្រូវបានផ្តល់ជូនក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌដូចខាងក្រោម ៖

ក- អាជ្ញាធរវិទ្យាសាស្ត្រនៃរដ្ឋនាំចូលបានផ្តល់យោបល់ថា គោលបំណងនៃការនាំចូលនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ការបន្តរស់រានមានជីវិតនៃប្រភេទពាក់ព័ន្ធនោះឡើយ ។

ខ- អាជ្ញាធរវិទ្យាសាស្ត្រនៃរដ្ឋនាំចូលបានយល់ព្រមថា អ្នកទទួលដែលបានធ្វើសំណើសុំមានមធ្យោបាយ ដើម្បីផ្តល់ជម្រក និងថែរក្សាសំណាករស់នោះដោយសមរម្យ ។

គ- អាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចូលបានបញ្ជាក់ជាវិជ្ជមានថា សំណាកនៃប្រភេទដែលបានស្នើសុំនាំចូលនោះ មិនមែនសម្រាប់បម្រើឱ្យគោលបំណងជាចម្បងធ្វើពាណិជ្ជកម្មទេ។

p

៤- ការនាំចេញបន្តលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ I ត្រូវទាមទារឲ្យផ្តល់ និងបង្ហាញជាមុននូវវិញ្ញាបនបត្របញ្ជាក់ការនាំចេញបន្ត ។ វិញ្ញាបនបត្របញ្ជាក់ការនាំចេញបន្ត ត្រូវបានផ្តល់ជូនក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌដូចខាងក្រោម ៖

ក- អាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចេញបន្តបានបញ្ជាក់ថា សំណាកនៃប្រភេទនោះ ត្រូវបាននាំចូលមកក្នុងរដ្ឋនោះ ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

ខ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញបន្ត បានបញ្ជាក់ថា គ្រប់សំណាករស់នឹងទទួលបានការរៀបចំ និងដឹកជញ្ជូនត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យដែលបង្ករបួស ធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ និង

គ- អាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចេញបន្តបានបញ្ជាក់ថា លិខិតអនុញ្ញាតនាំចូលត្រូវបានផ្តល់ឱ្យសម្រាប់សំណាករស់នោះរួចហើយ ។

៥- ការនាំមកពីសមុទ្រនូវសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ I ត្រូវមានវិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចូលជាមុន ។ វិញ្ញាបនបត្របញ្ជាក់ត្រូវបានផ្តល់ជូនក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌដូចខាងក្រោម ៖

ក- អាជ្ញាធរវិទ្យាសាស្ត្រនៃរដ្ឋនាំចូលបានផ្តល់ព័ត៌មានថា ការនាំចូលនេះមិនបានធ្វើឱ្យខូចខាតដល់ការរស់រានមានជីវិតបន្តទៅទៀតនៃប្រភេទនោះឡើយ ។

ខ- អាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចូលបានបញ្ជាក់ថា អ្នកទទួលដែលបានធ្វើសំណើសុំការនាំចូលមានមធ្យោបាយសមស្របដើម្បីផ្តល់ជម្រក និងថែរក្សាសំណាករស់នោះដោយសមរម្យ ។

គ- អាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចូលបានបញ្ជាក់ថា សំណាករស់នៃប្រភេទដែលបានស្នើសុំនាំចូលនោះ មិនមែនសម្រាប់បម្រើឱ្យគោលបំណងជាចម្បងនៃការធ្វើពាណិជ្ជកម្មឡើយ។

មាត្រា ៤
បញ្ញត្តិសម្រាប់ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ II

១- ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ II ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ ។

២- ការនាំចេញសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ II ត្រូវទាមទារឱ្យផ្តល់ និងបង្ហាញជាមុននូវលិខិតអនុញ្ញាតនាំចេញ ។ លិខិតអនុញ្ញាតនាំចេញត្រូវបានផ្តល់ជូនក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌ

p

ដូចខាងក្រោម ៖

ក- អាជ្ញាធរវិទ្យាសាស្ត្រនៃរដ្ឋនាំចេញបានផ្តល់ព័ត៌មានថា ការនាំចេញនេះមិនធ្វើឱ្យខូចខាតដល់ការរស់រានមានជីវិតបន្តទៅទៀតនៃប្រភេទទាំងនេះឡើយ ។

ខ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញបានបញ្ជាក់ថា សំណាកមិនត្រូវទទួលបាន ដោយផ្ទុយច្បាប់សម្រាប់ការការពារសត្វ និងរុក្ខជាតិព្រៃទាំងឡាយរបស់រដ្ឋ និង

គ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញបានបញ្ជាក់ថា គ្រប់សំណាករស់នឹងទទួលបានការរៀបចំ និងដឹកជញ្ជូនត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យដែលបង្ករបួស ធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ ។

៣- អាជ្ញាធរវិទ្យាសាស្ត្រនៃភាគីនីមួយៗ ត្រូវតាមដានត្រួតពិនិត្យ ទាំងការផ្តល់លិខិតអនុញ្ញាតនាំចេញនៃសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ II និងការនាំចេញជាក់ស្តែងនៃសំណាកនោះ ។ នៅពេលណាដែលអាជ្ញាធរវិទ្យាសាស្ត្របានរកឃើញថា ការនាំចេញនូវសំណាកនៃប្រភេទណាមួយគួរតែធ្វើការកំណត់ដើម្បីថែរក្សាប្រភេទនោះឱ្យស្ថិតនៅក្នុងកំរិតចន្លោះសមស្របជាមួយនឹងតួនាទីរបស់វា ក្នុងប្រព័ន្ធមជ្ឈដ្ឋានដែលវារស់នៅ និងប្រសើរជាងការនាំយកប្រភេទនោះទៅចុះក្នុងឧបសម្ព័ន្ធ I របស់អនុសញ្ញានេះ អាជ្ញាធរវិទ្យាសាស្ត្រត្រូវផ្តល់យោបល់ដល់អាជ្ញាធរគ្រប់គ្រងនូវវិធានការសមស្រប ដើម្បីដាក់កំហិតលើការផ្តល់លិខិតអនុញ្ញាតនាំចេញសំណាកនៃប្រភេទនោះ ។

៤- ការនាំចូលសំណាកនៃប្រភេទមួយក្នុងឧបសម្ព័ន្ធ II ត្រូវទាមទារឱ្យបង្ហាញជាមុននូវលិខិតអនុញ្ញាតនាំចេញ ឬវិញ្ញាបនបត្រនាំចេញបន្ត មុននឹងធ្វើការនាំចូល ។

៥- ការនាំចេញបន្តសំណាកនៃប្រភេទណាមួយក្នុងឧបសម្ព័ន្ធ II ត្រូវទាមទារឱ្យផ្តល់ និងបង្ហាញជាមុននូវវិញ្ញាបនបត្រនាំចេញបន្ត។ វិញ្ញាបនបត្រនាំចេញបន្ត ត្រូវបានផ្តល់ជូនក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌដូចខាងក្រោម ៖

ក- អាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចេញបន្តបានបញ្ជាក់ថា សំណាកនៃប្រភេទត្រូវបាននាំចូលមកក្នុងរដ្ឋនេះ ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ និង

ខ-អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញបន្តត្រូវបញ្ជាក់ថា គ្រប់សំណាករស់នឹងទទួលបានការរៀបចំ និងដឹកជញ្ជូនត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យដែលបង្ករបួស ធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ ។

p

៦- ការនាំមកពីសមុទ្រនូវសំណាកនៃប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ II ចាំបាច់ត្រូវទាមទារឱ្យផ្តល់ និងបង្ហាញជាមុន នូវវិញ្ញាបនបត្រចេញដោយអាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចូលនោះ ។ វិញ្ញាបនបត្រនាំមកពីសមុទ្រត្រូវបានផ្តល់ជូន ក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌដូចខាងក្រោម ៖

ក- អាជ្ញាធរវិទ្យាសាស្ត្រនៃរដ្ឋនាំចូលបានផ្តល់ព័ត៌មានថា ការនាំចូលនោះមិនធ្វើឱ្យខូចខាតដល់ការរស់រានមានជីវិតបន្តទៅទៀតនៃប្រភេទនោះឡើយ ។

ខ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចូលត្រូវបញ្ជាក់ថាគ្រប់សំណាករស់ នឹងទទួលបានការរៀបចំនិងដឹកជញ្ជូនត្រឹមត្រូវដើម្បីកាត់បន្ថយហានិភ័យដែលបង្ករបួសធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ ។

៧- វិញ្ញាបនបត្រដូចមានចែងក្នុងកថាខណ្ឌទី ៦ នៃមាត្រានេះ អាចផ្តល់ជូនបានដោយផ្អែកលើការផ្តល់យោបល់របស់អាជ្ញាធរវិទ្យាសាស្ត្រ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរវិទ្យាសាស្ត្រជាតិ ឬអាជ្ញាធរវិទ្យាសាស្ត្រអន្តរជាតិពេលណាសមស្រប ដោយមិនត្រូវចំណាយពេលវេលាឱ្យលើសពីមួយឆ្នាំឡើយ សម្រាប់គ្រប់សំណាកទាំងអស់ដែលត្រូវនាំចូលក្នុងរយៈពេលនោះ ។

មាត្រា ៥
បញ្ញត្តិសម្រាប់ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ III

១- ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទដែលកំណត់ក្នុងឧបសម្ព័ន្ធ III ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ ។

២- ការនាំចេញសំណាកនៃប្រភេទណាមួយដែលកំណត់ក្នុងឧបសម្ព័ន្ធ III ពីរដ្ឋមួយដែលបានស្នើសុំដាក់បញ្ចូលប្រភេទនេះទៅក្នុងឧបសម្ព័ន្ធ III ត្រូវទាមទារឱ្យផ្តល់ និងបង្ហាញជាមុននូវលិខិតអនុញ្ញាតនាំចេញ ។ លិខិតអនុញ្ញាតនាំចេញត្រូវបានផ្តល់ជូន ក្រោយពីបានបំពេញរួចរាល់នូវលក្ខខណ្ឌដូចខាងក្រោម ៖

ក- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញត្រូវបញ្ជាក់ថា សំណាកមិនត្រូវទទួល បានដោយផ្ទុយនឹងច្បាប់សម្រាប់ការពារសត្វនិងរុក្ខជាតិព្រៃទាំងឡាយរបស់រដ្ឋ និង

ខ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចេញត្រូវបញ្ជាក់ថា គ្រប់សំណាករស់នឹងទទួលបានការរៀប

ចំនិងដឹកជញ្ជូនត្រឹមត្រូវដើម្បីកាត់បន្ថយហានិភ័យដែលបង្ករបួស ធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ ។

៣- ការនាំចូលសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ III ត្រូវបង្ហាញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមជាមុន លើកលែងតែករណីដែលត្រូវអនុវត្តបញ្ញត្តិក្នុងកថាខណ្ឌទី ៤ នៃមាត្រានេះ ។ ចំពោះការនាំចូលមកពីរដ្ឋដែលបានសុំចុះបញ្ជីប្រភេទនោះទៅក្នុងឧបសម្ព័ន្ធ III ត្រូវមានលិខិតអនុញ្ញាតនាំចេញពីរដ្ឋនោះ ។

៤- ក្នុងករណីនាំចេញបន្ត វិញ្ញាបនបត្រដែលបានផ្តល់ឱ្យដោយអាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចេញបន្តដែលសំណាកត្រូវបានទទួលការកែច្នៃរួច ឬកំពុងធ្វើការនាំចេញបន្ត វិញ្ញាបនបត្រនោះ ត្រូវបានទទួលស្គាល់សម្រាប់ធ្វើជាភ័ស្តុតាងថា បទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះត្រូវបានអនុវត្ត ចំពោះសំណាកជាប់ពាក់ព័ន្ធនោះរួចហើយ។

មាត្រា ៦
លិខិតអនុញ្ញាត និង វិញ្ញាបនបត្រ

១- លិខិតអនុញ្ញាត និងវិញ្ញាបនបត្រដែលត្រូវផ្តល់ឱ្យក្រោមបទប្បញ្ញត្តិនៃមាត្រា ៣, ៤ និង៥ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ ។

២- លិខិតអនុញ្ញាតនាំចេញ ត្រូវមានព័ត៌មានបញ្ជាក់ដូចមានក្នុងគំរូភ្ជាប់ជាឧបសម្ព័ន្ធ IV និងអាចប្រើប្រាស់បានតែក្នុងរយៈពេល៦ខែ គិតចាប់ពីថ្ងៃដែលបានផ្តល់ឱ្យ ។

៣- លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រនីមួយៗ ត្រូវមានវិលេខចំណងជើងរបស់អនុសញ្ញានេះ ព្រមទាំងឈ្មោះ និងត្រាសម្គាល់របស់អាជ្ញាធរគ្រប់គ្រងដែលបានផ្តល់ឱ្យ និងលេខលិខិត ដែលកំណត់ដោយអាជ្ញាធរគ្រប់គ្រង ។

៤- ឯកសារចម្លងនីមួយៗនៃលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ដែលចេញឲ្យដោយអាជ្ញាធរគ្រប់គ្រងមានសមត្ថកិច្ចត្រូវមានបញ្ជាក់ថាជាច្បាប់ចម្លងតែប៉ុណ្ណោះ ហើយគ្មានច្បាប់ចម្លងណាមួយអាចត្រូវបានប្រើជំនួសឱ្យច្បាប់ដើមបានឡើយ លើកលែងតែមានចំណារយល់ព្រមពីលើលិខិតចម្លងនោះដោយអាជ្ញាធរគ្រប់គ្រង ។

៥- រាល់ការបញ្ជូនសំណាកមួយលើកៗ ត្រូវមានលិខិតអនុញ្ញាត ឬវិញ្ញាបនបត្របញ្ជាក់ដោយឡែកពីគ្នា ។

p

៦- *អាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចូលសំណាកណាមួយ ត្រូវបញ្ជាក់នូវមោឃភាព និងរក្សាទុកលិខិតអនុញ្ញាតនាំចេញ ឬវិញ្ញាបនបត្រសម្រាប់ការនាំចេញបន្តព្រមឯកសារទាក់ទងនឹងលិខិតអនុញ្ញាតឱ្យនាំចូល ដែលបានបង្ហាញពាក់ព័ន្ធនឹងការនាំចូលសំណាកនោះ ។*

៧- *ប្រសិនបើសមស្រប និងអាចធ្វើទៅបានអាជ្ញាធរគ្រប់គ្រងអាចប្រថាប់សញ្ញាសម្គាល់លើសំណាកនីមួយៗ ដើម្បីសម្រួលដល់ការធ្វើអត្តសញ្ញាណកម្មសំណាកនៃប្រភេទៗ សម្រាប់គោលបំណងទាំងនេះសញ្ញាសម្គាល់មានន័យថា រាល់ស្នាមផ្តិតដែលអាចអានបាន ត្រា ឬមធ្យោបាយសមស្របដើម្បីកំណត់អត្តសញ្ញាណរបស់សំណាកដែលរចនាតាមរបៀបណាមួយ ដែលធ្វើឱ្យការបន្លំ ធ្វើតាមដោយបុគ្គលដែលគ្មានសិទ្ធិមានការពិបាកបំផុត។*

មាត្រា ៧

អញ្ញត្រកម្ម និងបទប្បញ្ញត្តិពិសេសទាក់ទងនឹងពាណិជ្ជកម្ម

១- *បទប្បញ្ញត្តិនៃមាត្រា ៣, ៤ និង៥ មិនត្រូវបានអនុវត្តចំពោះការដឹកជញ្ជូនសំណាកឆ្លងកាត់ ឬការដឹកជញ្ជូន ផ្ទេរសំណាកឆ្លងកាត់ឬក្នុងបូរណភាពដែនដីរបស់ភាគីមួយនៅក្នុងពេលដែលសំណាកទាំងនោះកំពុងស្ថិតក្រោមការត្រួតពិនិត្យរបស់គយ ។*

២- *នៅពេលដែលអាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចេញ ឬនាំចេញបន្តបានបញ្ជាក់ជាវិជ្ជមានថា សំណាកនៃប្រភេទនោះត្រូវបានទទួលមុនពេលដែលបទប្បញ្ញត្តិនៃអនុសញ្ញានេះ អនុវត្តទៅលើប្រភេទនោះ បទប្បញ្ញត្តិនៃមាត្រា ៣, ៤ និង៥ មិនត្រូវបានអនុវត្តចំពោះសំណាកនោះទេ ហើយអាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចេញនោះ អាចផ្តល់វិញ្ញាបនបត្របញ្ជាក់ឱ្យនាំចេញបាន ។*

៣- *បទប្បញ្ញត្តិនៃមាត្រា ៣, ៤ និង៥ មិនត្រូវអនុវត្តចំពោះសំណាកទាំងឡាយដែលជារបស់ផ្ទាល់ខ្លួន ឬរបស់ប្រើប្រាស់នៅក្នុងផ្ទះទេ ។*

ការលើកលែងនេះមិនត្រូវអនុវត្ត ៖

ក- *ចំពោះករណីសំណាកនៃប្រភេទណាមួយមាននៅក្នុងឧបសម្ព័ន្ធ I ត្រូវបានទទួលកាន់កាប់ដោយម្ចាស់កម្មសិទ្ធិក្រៅពីរដ្ឋនៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន ហើយដែលកំពុងធ្វើការនាំចូលមកក្នុងរដ្ឋដែលកម្មសិទ្ធិករនោះ កំពុងរស់នៅជាអចិន្ត្រៃយ៍ ឬ*

ខ- *ចំពោះករណីសំណាកនៃប្រភេទណាមួយមាននៅក្នុងឧបសម្ព័ន្ធ II ៖*

p

(១)- សំណាកនោះត្រូវបានទទួលកាន់កាប់ដោយម្ចាស់កម្មសិទ្ធិក្រៅពីរដ្ឋ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន និងជារដ្ឋដែលសំណាកនៃប្រភេទនោះត្រូវបានប្រមូលមកពីក្នុងព្រៃធម្មជាតិ ។

(២)- សំណាកនោះកំពុងនាំចូលទៅក្នុងរដ្ឋដែលកម្មសិទ្ធិករ មានលំនៅដ្ឋានជាអចិន្ត្រៃយ៍។

(៣)-រដ្ឋដែលរងការបាត់បង់ពូជពីព្រៃធម្មជាតិតម្រូវឱ្យមានលិខិតអនុញ្ញាតនាំចេញសំណាក នៃប្រភេទនោះមុនពេលធ្វើការនាំចេញ លើកលែងតែអាជ្ញាធរគ្រប់គ្រងបានបញ្ជាក់ជាវិជ្ជមានថា សំណាកនោះត្រូវបានទទួលមុនពេលដែលបទប្បញ្ញត្តិនៃអនុសញ្ញានេះអនុវត្តចំពោះសំណាកនោះ ។

៤- សំណាកនៃប្រភេទសត្វនៅក្នុងឧបសម្ព័ន្ធ I ដែលបានមកពីការបង្កាត់ពូជ សម្រាប់គោលបំណងធ្វើពាណិជ្ជកម្ម ឬសំណាកនៃប្រភេទរុក្ខជាតិនៅក្នុងឧបសម្ព័ន្ធ I ដែលបានមកពីការធ្វើពហុកម្មដោយសិប្បនិម្មិត សម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវបានចាត់ទុកជាសំណាកនៃប្រភេទដែលស្ថិតក្នុងឧបសម្ព័ន្ធ II ។

៥- នៅពេលអាជ្ញាធរគ្រប់គ្រងនៃរដ្ឋនាំចេញបានបញ្ជាក់ថា សំណាកណាមួយនៃប្រភេទសត្វដែលត្រូវបានបង្កាត់ពូជ ឬសំណាកនៃប្រភេទរុក្ខជាតិដែលត្រូវបានធ្វើពហុកម្មដោយសិប្បនិម្មិត ឬផ្នែកណាមួយនៃប្រភេទសត្វ ឬរុក្ខជាតិព្រៃនោះ ឬផលិតផលដែលបានកែច្នៃពីសំណាកនោះ វិញ្ញាបនបត្រដែលចេញដោយអាជ្ញាធរគ្រប់គ្រងពីរដ្ឋនោះ ត្រូវបានទទួលស្គាល់ជំនួសរាល់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រទាំងឡាយ ដែលស្ថិតក្រោមតម្រូវការនៃបទប្បញ្ញត្តិនៃមាត្រា ៣, ៤ និង៥ ។

៦- បទប្បញ្ញត្តិនៃមាត្រា ៣, ៤ និង៥ មិនត្រូវអនុវត្តទៅលើកម្ចីមិនមែនសម្រាប់ធ្វើពាណិជ្ជកម្ម ការធ្វើអំណោយ ឬការផ្លាស់ប្តូររវាងអ្នកវិទ្យាសាស្ត្រ ឬវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រដែលបានចុះបញ្ជីដោយអាជ្ញាធរគ្រប់គ្រងរបស់រដ្ឋ និងតិណ្ណាល័យនៃសំណាក សារៈមន្ទីរថែរក្សា សម្ងួត ឬតម្កល់ទុកសំណាកផ្សេងទៀត និងរូបធាតុរុក្ខជាតិមានជីវិតដែលមានស្លាកសញ្ញាចេញឱ្យ ឬយល់ព្រមដោយអាជ្ញាធរគ្រប់គ្រង ។

៧- អាជ្ញាធរគ្រប់គ្រងនៃរដ្ឋមួយ អាចលើកលែងនូវតម្រូវការនៃមាត្រា ៣, ៤ និង៥ និងអាចអនុញ្ញាតការចលនាដោយគ្មានលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រចំពោះសំណាកដែលជារបស់ផ្នែកសួនសត្វចល័ត ក្រុមសៀករហ៊េសកម្ម ក្រុមតាំងសត្វព្រៃ ពិព័រណ៍រុក្ខជាតិ ឬពិព័រណ៍គោចរដ៏ទៃទៀតនៅពេលដែល ៖

p

ក- អ្នកនាំចេញ ឬអ្នកនាំចូលបានចុះបញ្ជីយ៉ាងលំអិត នូវសំណាកនៃប្រភេទជាមួយអាជ្ញាធរគ្រប់គ្រងនោះ រួចហើយ។

ខ- សំណាកដែលមាននៅក្នុងលក្ខណៈវិនិច្ឆ័យ ដែលគូសបញ្ជាក់នៅក្នុងកថាខណ្ឌទី៦ ឬ ៥ នៃមាត្រានេះ ។ និង

គ- អាជ្ញាធរគ្រប់គ្រងរបស់រដ្ឋនាំចូលបញ្ជាក់ថា គ្រប់សំណាករស់នឹងទទួលបានការដឹកជញ្ជូន និងថែទាំត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យដែលបង្ករបួសធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ ។

មាត្រា ៨
វិធានការដែលត្រូវប្រកាន់យកដោយភាគីជាសមាជិក

១- ភាគីជាសមាជិកទាំងអស់ត្រូវមានវិធានការសមស្រប ដើម្បីអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ និងហាមឃាត់ការធ្វើពាណិជ្ជកម្មសំណាកទាំងឡាយ ដែលល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។ វិធានការទាំងនេះរួមមាន ៖

ក- ដាក់ទណ្ឌកម្មលើការធ្វើពាណិជ្ជកម្ម ឬការកាន់កាប់ធ្វើជាកម្មសិទ្ធិលើសំណាកទាំងនោះ ឬត្រូវមានវិធានការលើករណីទាំងពីរ និង

ខ- អំណាចរឹបអូសធ្វើជាទ្រព្យសម្បត្តិរដ្ឋ ឬចាប់បញ្ជូនត្រឡប់ទៅកាន់រដ្ឋដែលបានធ្វើការនាំចេញវិញនូវប្រភេទទាំងនោះ ។

២- បន្ថែមលើវិធានការដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ក្នុងករណីចាំបាច់ភាគីមួយ ត្រូវបង្កើតយន្តការណាមួយដើម្បីទូទាត់ចំណាយដែលបានកើតឡើងដោយសារការអនុវត្តសកម្មភាពរឹបអូសយកសំណាកនៃប្រភេទដែលត្រូវបានគេធ្វើការជួញដូរល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

៣- ភាគីទាំងឡាយត្រូវធានាថា សំណាកទាំងនោះត្រូវឆ្លងកាត់វិធីត្រួតពិនិត្យចំពោះការធ្វើពាណិជ្ជកម្មលើសំណាកនោះបានយ៉ាងលឿនបំផុត ។ ដើម្បីសម្រួលដល់ដំណើរការនេះ ភាគីមួយអាចកំណត់ច្រកចេញនិងច្រកចូល ដែលសំណាកនោះត្រូវនាំចេញ និងត្រូវនាំចូល សម្រាប់ការត្រួតពិនិត្យពេលសំណាកនោះមកដល់ ។ ភាគីទាំងអស់ត្រូវធានាបន្ថែមទៀតថា សំណាករស់នឹងទទួលបាន

p

ការរៀបចំ និងដឹកជញ្ជូនត្រឹមត្រូវ ដើម្បីកាត់បន្ថយហានិភ័យដែលបង្ករបួស ធ្វើឱ្យខូចសុខភាព ឬការប្រព្រឹត្តយ៉ាងឃោរឃៅ ។

៤- នៅពេលសំណាករស់ត្រូវបានរឹបអូស ដោយសារតែបានប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ៖

ក សំណាកត្រូវប្រគល់ជូនអាជ្ញាធរគ្រប់គ្រងនៃរដ្ឋដែលបានធ្វើការរឹបអូស ។

ខ- បន្ទាប់ពីការពិគ្រោះយោបល់ជាមួយរដ្ឋនាំចេញ អាជ្ញាធរគ្រប់គ្រងនៃរដ្ឋ ដែលបានរឹបអូស សំណាកត្រូវបញ្ជូនសំណាកទៅឱ្យរដ្ឋនាំចេញវិញ។ រដ្ឋនាំចេញត្រូវទទួលបន្ទុកលើចំណាយពាក់ព័ន្ធនឹងការងារនេះ ឬត្រូវបញ្ជូនទៅកាន់មជ្ឈមណ្ឌលសង្គ្រោះ ឬកន្លែងផ្សេងទៀត ដែលអាជ្ញាធរគ្រប់គ្រងយល់ឃើញថាសមស្របនិងមានសង្គតភាពជាមួយនឹងគោលបំណងនៃការអនុវត្តអនុសញ្ញានេះ ។ និង

គ- អាជ្ញាធរគ្រប់គ្រងអាចទទួលយកមតិយោបល់ពីអាជ្ញាធរវិទ្យាសាស្ត្រ ឬអាចពិគ្រោះជាមួយលេខាធិការដ្ឋានអនុសញ្ញាសាយតេស ដើម្បីសម្របសម្រួលការសម្រេចចិត្ត តាមវាក្យខណ្ឌ (ខ) នៃកថាខណ្ឌនេះព្រមទាំងការជ្រើសរើសមជ្ឈមណ្ឌលសង្គ្រោះ ឬកន្លែងផ្សេងទៀត។

៥- មជ្ឈមណ្ឌលសង្គ្រោះដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រានេះមានន័យថា ជាមជ្ឈមណ្ឌលមួយដែលបានរៀបចំដោយអាជ្ញាធរគ្រប់គ្រង ដើម្បីថែរក្សាសុខុមាលភាពសំណាកនៅរស់ ជាពិសេសសំណាកនៅរស់ដែលបាន មកពីការចាប់រឹបអូស ។

៦- ភាគីនីមួយៗត្រូវរក្សាទុកសំណុំឯកសារនៃការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទទាំងឡាយ ដែលចុះក្នុងបញ្ជីឧបសម្ព័ន្ធ I, II និង III របស់អនុសញ្ញា ។ គ្រប់សំណុំឯកសារ ត្រូវមាន ៖

ក- ឈ្មោះ អាសយដ្ឋានអ្នកនាំចេញ និងអ្នកនាំចូល និង

ខ- លេខបញ្ជីរបស់ប្រភេទលិខិតអនុញ្ញាត និងវិញ្ញាបនបត្រដែលបានផ្តល់ឱ្យរដ្ឋទាំងអស់ ដែលទាក់ទិននឹងការធ្វើពាណិជ្ជកម្មចូលគ្នា ឬកើតមានចំនួន ឬបរិមាណ និងប្រភេទនៃសំណាក ឈ្មោះរបស់ប្រភេទ រួមទាំងកំណត់បញ្ជីឧបសម្ព័ន្ធ I, II និង III ទំហំ (ខ្នាត) និងភេទរបស់សំណាកនោះ។

៧- ភាគីនីមួយៗត្រូវរៀបចំរបាយការណ៍ ស្តីពីការអនុវត្តអនុសញ្ញានេះ តាមការកំណត់ រួចបញ្ជូនទៅឱ្យលេខាធិការដ្ឋានរបស់អនុសញ្ញា ។ របាយការណ៍នេះរួមមាន ៖

p

ក- របាយការណ៍ប្រចាំឆ្នាំដែលនៅក្នុងនោះត្រូវមាន សេចក្តីសង្ខេបព័ត៌មានដូចមានបញ្ជាក់ជូននៅក្នុងវាក្យខណ្ឌ (ខ) នៃកថាខណ្ឌទី ៦នៃមាត្រានេះ ។

ខ- របាយការណ៍ ២ឆ្នាំ ដែលមាននៅក្នុងនោះត្រូវមានព័ត៌មានស្តីពីច្បាប់ ការធ្វើនិយ័តកម្ម និងវិធានការរដ្ឋបាលដែលត្រូវបានអនុវត្ត ក្នុងការពង្រឹងការអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ។

៨- ព័ត៌មានដែលលើកឡើងនៅក្នុងកថាខណ្ឌទី ៧ នៃមាត្រានេះ ត្រូវផ្សព្វផ្សាយជាសាធារណៈ លើកលែងតែព័ត៌មានណាដែលពុំមានសង្គតិភាពស្របនឹងច្បាប់នៃភាគីពាក់ព័ន្ធ ។

មាត្រា ៩
អាជ្ញាធរគ្រប់គ្រង និងអាជ្ញាធរវិទ្យាសាស្ត្រ

១- សម្រាប់គោលបំណងនៃការអនុវត្តអនុសញ្ញានេះ ភាគីជាសមាជិកនីមួយៗត្រូវរៀបចំបង្កើតឡើងនូវ ៖

ក- អាជ្ញាធរគ្រប់គ្រងមួយ ឬច្រើនដែលមានសមត្ថភាពចេញលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ក្នុងនាមភាគីជាសមាជិក និង

ខ- អាជ្ញាធរវិទ្យាសាស្ត្រមួយ ឬច្រើន ។

២- រដ្ឋទទួលតម្កល់លិខិតផ្តល់សច្ចាប័ន លិខិតទទួលស្គាល់ លិខិតយល់ព្រម ឬលិខិតសុំចូលជាសមាជិករបស់រដ្ឋនីមួយៗត្រូវជូនដំណឹងទៅរដ្ឋាភិបាលនៃរដ្ឋម្ចាស់លិខិតទាំងនោះនូវឈ្មោះ និងអាសយដ្ឋានរបស់អាជ្ញាធរគ្រប់គ្រង ដែលមានសិទ្ធិធ្វើទំនាក់ទំនងជាមួយភាគីជាសមាជិកដទៃទៀត និងជាមួយលេខាធិការដ្ឋាននៃអនុសញ្ញា ។

៣- រាល់ការផ្លាស់ប្តូរអង្គការចាត់តាំង ឬសិទ្ធិអំណាច ដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រានេះ ភាគីពាក់ព័ន្ធត្រូវទាក់ទងទៅលេខាធិការដ្ឋាននៃអនុសញ្ញានេះ ដើម្បីបញ្ជូនព័ត៌មានបន្តទៅឱ្យភាគីដទៃទៀតទាំងអស់បានដឹង ។

៤- អាជ្ញាធរគ្រប់គ្រងនីមួយៗ ដែលត្រូវបានតែងតាំងស្របតាមកថាខណ្ឌទី២ នៃមាត្រានេះ ប្រសិនបើមានតម្រូវការពីលេខាធិការដ្ឋាននៃអនុសញ្ញា ឬអាជ្ញាធរគ្រប់គ្រងនៃភាគីដទៃទៀត ត្រូវផ្ញើតែមប្រិយ៍ត្រា ឬសញ្ញាផ្សេងទៀតដែលបានប្រើសម្រាប់បញ្ជាក់យថាភាពនៃលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រទាំងឡាយដល់លេខាធិការដ្ឋាន ឬអាជ្ញាធរគ្រប់គ្រងនៃរដ្ឋដទៃទៀតនោះ។

p

មាត្រា ១០
ពាណិជ្ជកម្មជាមួយរដ្ឋដែលមិនមែនជាភាគីនៃអនុសញ្ញា

ចំពោះការនាំចេញប្រហាក់ប្រហែលគ្នា ឬការនាំចេញបន្ត ឬការនាំចូលពីរដ្ឋដែលមិនមែនជាភាគីនៃអនុសញ្ញានេះ ភាគីផ្សេងទៀតអាចទទួលឯកសារចេញដោយអាជ្ញាធរមានសមត្ថកិច្ចរដ្ឋដែលមិនមែនជាភាគីនោះ ដែលសមស្របតាមតម្រូវការរបស់អនុសញ្ញាពាក់ព័ន្ធនឹងលិខិតអនុញ្ញាត នឹងវិញ្ញាបនបត្រ។

មាត្រា ១១
សន្និសីទនៃភាគី

១-ក្នុងអំឡុងពេលមិនលើសពី២ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន លេខាធិការដ្ឋាននៃអនុសញ្ញានេះ ត្រូវរៀបចំអង្គសន្និសីទបណ្តារដ្ឋជាសមាជិក ។

២- បន្ទាប់មកលេខាធិការដ្ឋាន ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់យ៉ាងតិចមួយដងក្នុងរយៈពេលពីរឆ្នាំ លើកលែងតែសន្និសីទសំរេចផ្សេង និងរៀបចំកិច្ចប្រជុំវិសាមញ្ញនៅពេលណាក៏បានកាលណាមានការស្នើសុំជាលាយល័ក្ខអក្សរយ៉ាងតិច ១/៣ (មួយភាគបី) នៃចំនួនភាគីទាំងអស់ ។

៣- ក្នុងកិច្ចប្រជុំ ទោះជាសាមញ្ញ ឬវិសាមញ្ញ ភាគីទាំងអស់ត្រូវពិនិត្យឡើងវិញនូវការអនុវត្តអនុសញ្ញានេះ ហើយអាច ៖

ក-រៀបចំជាបទប្បញ្ញត្តិណាដែលចាំបាច់ សម្រាប់ឲ្យលេខាធិការដ្ឋានបំពេញភារកិច្ចរបស់ខ្លួនបាន និងអនុម័តលើបទប្បញ្ញត្តិស្តីពីហិរញ្ញវត្ថុ ។

ខ- ពិនិត្យ ពិចារណា និងអនុម័តលើសំណើសុំធ្វើវិសោធនកម្មឧបសម្ព័ន្ធ I និង II ដោយអនុលោមតាមមាត្រា ១៥ ។

គ- ពិនិត្យឡើងវិញនូវវឌ្ឍនភាពក្នុងការស្តារ និងអភិរក្សប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមានចែងក្នុងឧបសម្ព័ន្ធ I, II និង III ។

ឃ- ទទួល និងពិចារណាលើរបាយការណ៍ ដែលបង្ហាញជូនដោយលេខាធិការដ្ឋាន ឬដោយភាគីណាមួយ ។

p

ង- លើកអនុសាសន៍ផ្សេងៗ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តអនុសញ្ញានេះ ។

៤- ក្នុងកិច្ចប្រជុំសាមញ្ញនីមួយៗ ភាគីទាំងអស់អាចកំណត់ពេលវេលា និងទីកន្លែងសម្រាប់កិច្ចប្រជុំសាមញ្ញលើកក្រោយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះ ។

៥- ក្នុងសម័យប្រជុំណាក៏ដោយ ភាគីទាំងអស់អាចកំណត់ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់សម័យប្រជុំ ។

៦- អង្គការសហប្រជាជាតិ ទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ និងភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ក៏ដូចជារដ្ឋដែលមិនមែនជាសមាជិកអនុសញ្ញានេះ អាចចាត់តំណាងឱ្យទៅចូលរួមក្នុងសន្និសីទក្នុងឋានៈជាអ្នកសង្កេតការណ៍ ដែលមិនមានសិទ្ធិចូលរួមបោះឆ្នោតឡើយ ។

៧- គ្រប់អង្គការ ឬភ្នាក់ងារបច្ចេកទេសដែលមានជំនាញលើការការពារអភិរក្ស ឬគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិព្រៃ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសម័យប្រជុំក្នុងនាមជាអ្នកសង្កេតការណ៍តាមការស្នើសុំ ។ លើកលែងតែមានការជំទាស់យ៉ាងតិច ១/៣ (មួយភាគបី) នៃសមាជិកដែលមានវត្តមានក្នុងដំណើរការនៃកិច្ចប្រជុំ ៖

ក- ចំពោះភ្នាក់ងារ ឬអង្គការអន្តរជាតិ ភ្នាក់ងាររដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារ និងអង្គការជាតិ

ខ- ចំពោះភ្នាក់ងារ ឬអង្គការក្រៅរដ្ឋាភិបាលជាតិដែលត្រូវបានទទួលស្គាល់ដោយរដ្ឋដែលពួកគេកំពុងស្ថិតនៅ ។ នៅពេលបានទទួលការអនុញ្ញាត អ្នកសង្កេតការណ៍ទាំងនេះ ត្រូវមានសិទ្ធិចូលរួម តែពុំមានសិទ្ធិបោះឆ្នោតឡើយ។

មាត្រា ១២
លេខាធិការដ្ឋាន

១- នៅពេលអនុសញ្ញានេះចូលជាធរមាន លេខាធិការម្នាក់ត្រូវបានតែងតាំងដោយនាយកប្រតិបត្តិកម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ។ លេខាធិការ អាចត្រូវបានជួយជ្រោមជ្រែងពីសំណាក់ភ្នាក់ងារអន្តររដ្ឋាភិបាល ឬអង្គការអន្តរជាតិ ឬភ្នាក់ងារ និងអង្គការនៃស្ថាប័នជាតិ ដែលមានបច្ចេកទេសក្នុងការការពារ អភិរក្ស និងគ្រប់គ្រងពពួកសត្វ និង រុក្ខជាតិព្រៃ ។

២- តួនាទីរបស់លេខាធិការដ្ឋានរួមមាន ៖

ក- រៀបចំ និងផ្តល់សេវាកម្មសម្រាប់រាល់សម័យប្រជុំនៃភាគីទាំងអស់ ។

p

ខ- បំពេញមុខងារតាមភារកិច្ចដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ១៥ និង១៦ នៃអនុសញ្ញានេះ ។

គ-ធ្វើការសិក្សាលើផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ ស្របតាមកម្មវិធីដែលត្រូវបានអនុញ្ញាតដោយសន្និសីទនៃភាគីជាសមាជិកដែលទីងរួមចំណែកដល់ការអនុវត្តអនុសញ្ញានេះ រួមបញ្ចូលទាំងការសិក្សាស្តង់ដាលើសំរាប់ការរៀបចំ និងការដឹកជញ្ជូនសំណាករស់ និងមធ្យោបាយសម្រាប់កំណត់ប្រភេទសត្វ និងរុក្ខជាតិព្រៃ ។

ឃ- សិក្សាលើរបាយការណ៍របស់ភាគីជាសមាជិកដែលបានផ្តល់ឱ្យ និងស្នើសុំព័ត៌មានបន្ថែមពីភាគី ជាសមាជិកសំដៅធានាការអនុវត្តអនុសញ្ញានេះ ។

ង-ជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីទាំងអស់ឲ្យផ្តោតទៅលើបញ្ហាពាក់ព័ន្ធនឹងគោលបំណងនៃការអនុវត្តអនុសញ្ញានេះ ។

ច-រៀបចំបោះពុម្ព និងផ្សព្វផ្សាយជូនដំណឹងជាទៀងទាត់ដល់គ្រប់ភាគីទាំងអស់ នូវគ្រប់ព័ត៌មានទាក់ទងនឹងការប្រែប្រួល ផ្លាស់ប្តូរប្រភេទមានចុះក្នុងឧបសម្ព័ន្ធ I, II និង III ដែលអាចជួយសម្រួលដល់ការកំណត់សំណាកប្រភេទដែលមានចុះនៅក្នុងឧបសម្ព័ន្ធទាំងបី ។

ឆ- រៀបចំធ្វើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាព និងការប្រតិបត្តិរបស់ខ្លួន និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញានេះ ព្រមទាំងរបាយការណ៍ផ្សេងៗទៀត សម្រាប់ដាក់ជូនសមាជិកក្នុងកិច្ចប្រជុំសមាជិកតាមតម្រូវការ។

ជ- រៀបចំរាល់បណ្តាអនុសាសន៍ពាក់ព័ន្ធទៅនឹងគោលបំណងនៃការអនុវត្តបទប្បញ្ញត្តិរបស់អនុសញ្ញានេះ ដោយរួមបញ្ចូលនូវការផ្លាស់ប្តូរព័ត៌មានខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ។

ឈ- បំពេញតួនាទីទៅតាមមុខងារដទៃទៀត ដែលភាគីជាសមាជិកទាំងអស់ប្រគល់ឲ្យ ។

មាត្រា ១៣
វិធានការអន្តរជាតិ

១- នៅពេលដែលលេខាធិការដ្ឋានបានទទួលព័ត៌មានបញ្ជាក់ច្បាស់ថា សំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ I ឬ II កំពុងទទួលឥទ្ធិពលអាក្រក់ដោយសារ ការធ្វើពាណិជ្ជកម្ម ឬបទប្បញ្ញត្តិរបស់អនុសញ្ញានេះ មិនបានអនុវត្តត្រឹមត្រូវទេនោះ លេខាធិការដ្ឋានត្រូវជូនព័ត៌មាននេះទៅកាន់អាជ្ញាធរគ្រប់គ្រងនៃភាគីមួយ ឬច្រើនពាក់ព័ន្ធ ។

p

២- នៅពេលដែលភាគីបានទទួលនូវព័ត៌មានដូចមានបញ្ជាក់ក្នុងកថាខណ្ឌទី១ខាងលើ ភាគីនោះត្រូវរាយការណ៍មកលេខាធិការដ្ឋាន ឱ្យបានទាន់ពេលវេលាតាមដែលអាចធ្វើទៅបាន នូវអង្គហេតុពាក់ព័ន្ធដែលច្បាប់បានអនុញ្ញាត និងត្រូវចាត់វិធានការសមស្របដើម្បីដោះស្រាយ បើភាគីនោះយល់ឃើញថា គួរមានការអង្កេតមួយ ភាគីត្រូវចេញការអនុញ្ញាតយ៉ាងច្បាស់លាស់ដល់បុគ្គលម្នាក់ឬច្រើន ដើម្បីធ្វើការអង្កេតនោះ។

៣- ព័ត៌មានដែលផ្តល់ដោយភាគី ឬជាលទ្ធផលនៃការអង្កេតដូចមានបញ្ជាក់ក្នុងកថាខណ្ឌទី២ នៃមាត្រានេះ ត្រូវតែបានទទួលការពិនិត្យឡើងវិញ ដោយសន្និសីទនៃភាគីលើកក្រោយ ដែលអាចផ្តល់នូវអនុសាសន៍ណាដែលសមស្របតែប៉ុណ្ណោះ ។

មាត្រា ១៤
ឥទ្ធិពលនៅលើច្បាប់ក្នុងប្រទេស និងអនុសញ្ញាអន្តរជាតិ

១- បទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ពុំមានផលប៉ះពាល់ទៅលើសិទ្ធិរបស់ភាគីជាសមាជិកចំពោះការអនុម័ត ៖

ក- វិធានការក្នុងស្រុកតឹងរ៉ឹងបំផុត ចំពោះការធ្វើពាណិជ្ជកម្ម ការចាប់ប្រមូល ការកាន់កាប់យកធ្វើជាកម្មសិទ្ធិ ឬការដឹកជញ្ជូនគ្រប់សំណាកនៃប្រភេទដែលមានក្នុងឧបសម្ព័ន្ធ I, II និង III ឬការហាមឃាត់ទាំងស្រុងរាល់សកម្មភាពដែលបានរៀបរាប់ខាងលើនេះ ឬ

ខ- វិធានការហាមឃាត់ដ៏តឹងរ៉ឹង ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មនៅក្នុងស្រុក ការចាប់ប្រមូល ការកាន់កាប់យកធ្វើជាកម្មសិទ្ធិ ឬការដឹកជញ្ជូនប្រភេទសត្វ ឬរុក្ខជាតិព្រៃ ដែលមិនមានក្នុងបញ្ជីឧបសម្ព័ន្ធ I, II ឬ III ។

២- បទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះពុំមានផលប៉ះពាល់ទៅលើបទប្បញ្ញត្តិនៃវិធានការ នៅក្នុងស្រុក ឬកាតព្វកិច្ចនានា របស់ភាគីជាសមាជិកត្រូវគោរពតាមសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិដែលទាក់ទិនទៅនឹងទិដ្ឋភាពផ្សេងនៃការធ្វើពាណិជ្ជកម្ម ការចាប់ប្រមូល ការកាន់កាប់ធ្វើជាកម្មសិទ្ធិ ឬការដឹកជញ្ជូនសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងនៅជាធរមាន ឬអាចចូលជាធរមានជាបន្តបន្ទាប់ រួមទាំងវិធានការពាក់ព័ន្ធនឹងកិច្ចការគយ សុខភាពសាធារណៈ ចត្តាឡីស័ក ឬផ្នែកភូតគាមអនាម័យនានា ។

៣- បទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ពុំមានផលប៉ះពាល់ទៅលើបទប្បញ្ញត្តិ ឬកាតព្វកិច្ចនៃការអនុវត្តសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធ ឬវិធានដែលអាចកើតមានរវាងភាគីនៅក្នុងអំឡុងពេលនៃការបង្កើតសហភាព ឬការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្នាក់តំបន់ ឬការរក្សាទុកវិធានការត្រួតពិនិត្យរួមគ្នារបស់គយអន្តរជាតិ និងការលុបបំបាត់វិធានការត្រួតពិនិត្យរបស់គយអន្តរជាតិ រវាងបណ្តាភាគីដែលពាក់ព័ន្ធដល់ដំណើរការធ្វើពាណិជ្ជកម្មក្នុងចំណោមរដ្ឋសមាជិកសហភាពនោះ ឬកិច្ចព្រមព្រៀង ។

៤- ចំពោះភាគីជាសមាជិកអនុសញ្ញានេះ ដែលជាសមាជិកនៃសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិ ដែលបានចូលជាធរមាននៅពេលតែមួយនៃការចូលជាធរមាននៃអនុសញ្ញានេះដែរ និងក្រោមបទប្បញ្ញត្តិ ដែលការការពារត្រូវបានអនុវត្តចំពោះប្រភេទក្នុងសមុទ្រនៅក្នុងឧបសម្ព័ន្ធ II ដែលត្រូវបានរួចផុតពីកាតព្វកិច្ចកំណត់ក្នុងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទនៅក្នុងឧបសម្ព័ន្ធ II ដែលត្រូវបានផ្ទុកក្នុងនាវាដែលបានចុះបញ្ជីនៅក្នុងរដ្ឋនោះ និងអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតនោះ ។

៥- ទោះបីមានបទប្បញ្ញត្តិក្នុងមាត្រា ៣, ៤ និង៥ ក៏ដោយ ក៏ការនាំចេញតាមវិធាននៃកថាខណ្ឌទី ៤ នៃមាត្រានេះ តម្រូវឱ្យមានតែវិញ្ញាបនបត្រពីអាជ្ញាធរគ្រប់គ្រងនៃភាគីនាំចូល ក្នុងន័យថាសំណាកត្រូវបានចាប់ប្រមូល អនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនោះ ។

៦- គ្មានបទប្បញ្ញត្តិណាមួយក្នុងអនុសញ្ញានេះ ធ្វើឱ្យប៉ះពាល់ដល់ការរៀបចំចងក្រង និងដំណើរការរៀបចំឯកសារច្បាប់ស្តីពីសមុទ្រ ដោយសន្និសីទអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ដែលបានកោះប្រជុំ អនុលោមតាមសេចក្តីសម្រេចលេខ ២៧៥០ C (XXV) របស់សន្និបាតនៃអង្គការសហប្រជាជាតិ និងដល់ការតវ៉ានៅពេលបច្ចុប្បន្ន ឬទៅអនាគត ហើយនិងទស្សនៈច្បាប់នៃរដ្ឋណាមួយពាក់ព័ន្ធនឹងច្បាប់សមុទ្រ និងទ្រង់ទ្រាយ និងវិសាលភាពឆ្នេរ និងយុត្តាធិការ នៃទង់ជាតិរបស់រដ្ឋនោះឡើយ ។

មាត្រា ១៥

ការធ្វើវិសោធនកម្មឧបសម្ព័ន្ធ I និង II

p

១- បទប្បញ្ញត្តិខាងក្រោមនេះ ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មក្នុងឧបសម្ព័ន្ធ I និង II នៅសម័យប្រជុំ នៃសន្និសីទភាគីទាំងអស់ ៖

ក- ភាគីជាសមាជិកនីមួយៗ អាចលើកសំណើសុំធ្វើវិសោធនកម្មឧបសម្ព័ន្ធ I និង II សម្រាប់សម័យប្រជុំលើកក្រោយ ។ អត្ថបទស្នើសុំធ្វើវិសោធនកម្មទាំងអស់ ត្រូវបញ្ជូនទៅលេខាធិការដ្ឋាន យ៉ាងតិច១៥០ (មួយរយហាសិប) ថ្ងៃមុនសម័យប្រជុំ ។ លេខាធិការដ្ឋានត្រូវពិគ្រោះយោបល់ជាមួយភាគីជាសមាជិកដទៃទៀត និងអង្គការដែលចាប់អារម្មណ៍លើការស្នើសុំធ្វើវិសោធនកម្មនេះ ដោយអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខណ្ឌ(ខ) និង(គ) នៃកថាខណ្ឌទី២ខាងក្រោមនៃមាត្រានេះ ហើយលេខាធិការដ្ឋានត្រូវជូនដំណឹងអំពីការឆ្លើយតបទាំងនោះទៅគ្រប់ភាគីជាសមាជិកវិញ ដោយមិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃមុនសម័យប្រជុំឡើយ ។

ខ- វិសោធនកម្មត្រូវអនុម័តយល់ព្រមដោយសម្លេង២/៣ (ពីរភាគបី)នៃភាគីជាសមាជិកចូលរួម និងមានសិទ្ធិបោះឆ្នោត ។ ក្នុងន័យនេះ ភាគីជាសមាជិកចូលរួម និងមានសិទ្ធិបោះឆ្នោត គឺភាគីជាសមាជិក ដែលមានវត្តមាន និងបានធ្វើការបោះឆ្នោតដោយជ្រើសយកសម្លេងគាំទ្រ ឬបដិសេធ ។ ភាគីដែលបោះឆ្នោតអនុប្បវាទ មិនត្រូវបានរាប់បញ្ចូលក្នុងចំនួនសរុប ២/៣ (ពីរភាគបី) សម្រាប់ធ្វើការអនុម័តសំណើសុំធ្វើវិសោធនកម្មឡើយ ។

គ- រាល់វិសោធនកម្មដែលបានអនុម័តដោយសម័យប្រជុំរួច ត្រូវចូលជាធរមានក្រោយរយៈពេល ៩០ (កៅសិប)ថ្ងៃ គិតពីថ្ងៃដែលបានអនុម័ត ដោយភាគីជាសមាជិកទាំងអស់ លើកលែងតែភាគីណាដែលបានធ្វើខ ដាក់លក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រានេះ។

២- បទប្បញ្ញត្តិខាងក្រោមនេះពាក់ព័ន្ធនឹងវិសោធនកម្មឧបសម្ព័ន្ធ I និង II ចន្លោះពេលប្រជុំរបស់សន្និសីទភាគីជាសមាជិក ៖

ក- ភាគីនិមួយៗ អាចស្នើសុំធ្វើវិសោធនកម្មចំពោះសំណាកនៃប្រភេទក្នុងឧបសម្ព័ន្ធ I និង II ដើម្បីកិច្ចប្រជុំធ្វើការពិចារណានូវចន្លោះកិច្ចប្រជុំនានា តាមរយៈការផ្ញើតាមប្រៃសណីយ៍ដូចមានជូនជ្រាប ក្នុងកថាខណ្ឌនេះ។

ខ- ចំពោះប្រភេទសត្វ ឬរុក្ខជាតិសមុទ្រ នៅពេលទទួលបានឯកសារស្នើសុំធ្វើវិសោធនកម្មភ្លាម លេខាធិការដ្ឋានត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីជាសមាជិកទាំងអស់។ លេខាធិការដ្ឋាន ត្រូវពិគ្រោះយោបល់ជាមួយអង្គការអន្តររដ្ឋាភិបាលដែលមានមុខងារទាក់ទងទៅនឹងប្រភេទស្នើ

p

សុំនោះ ដើម្បីទទួលបាននូវទិន្នន័យដែលអង្គការទាំងនោះផ្ដល់ឲ្យ និងជាទាការសម្រប សម្រួលដល់វិធានការអភិរក្ស ដែលអង្គការទាំងនោះបានអនុវត្ត ។ លេខាធិការដ្ឋានត្រូវ បញ្ជូនយោបល់ និងព័ត៌មានបានមកពីអង្គការទាំងនេះ និងរបកគំហើញ និងអនុសាសន៍ ផ្ទាល់របស់ខ្លួនដល់គ្រប់ភាគីជាសមាជិកឱ្យបានឆាប់បំផុត ដែលអាចធ្វើទៅបាន ។

គ- ចំពោះបណ្ដាប្រភេទ ក្រៅពីប្រភេទសត្វ និងរុក្ខជាតិសមុទ្រ នៅពេលទទួលបានឯកសារស្នើ សុំធ្វើវិសោធនកម្មភ្លាម លេខាធិការដ្ឋានត្រូវបញ្ជូនឯកសារទាំងនោះ ព្រមទាំងអនុសាសន៍ ផ្ទាល់របស់ខ្លួន ទៅភាគីជាសមាជិកទាំងអស់ជាបន្ទាន់។

ឃ- ក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃ ចាប់ពីពេលទទួលបានអនុសាសន៍ និងព័ត៌មានទាក់ទង នឹងវាក្យខណ្ឌ (ខ) និង(គ) នៃកថាខណ្ឌខាងលើនេះ ភាគីនីមួយៗអាចធ្វើការឆ្លើយតប ឬបញ្ជូនមកលេខាធិការដ្ឋានវិញ នូវមតិយោបល់លើសំណើសុំធ្វើវិសោធនកម្មនោះ ដោយ មានភ្ជាប់ជាមួយនូវព័ត៌មាន និងទិន្នន័យវិទ្យាសាស្ត្រពាក់ព័ន្ធ ។

ង- លេខាធិការដ្ឋានត្រូវបញ្ជូនចម្លើយ ដែលបានទទួល ព្រមទាំងអនុសាសន៍របស់ខ្លួនទៅភាគី ជាសមាជិកទាំងអស់ឲ្យបានឆាប់បំផុត។

ច- បើក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ចាប់ពីពេលបានជូនដំណឹងស្របតាមវាក្យខណ្ឌ (ង)នៃ កថាខណ្ឌខាងលើនេះ លេខាធិការដ្ឋានពុំបានទទួលយោបល់ជំទាស់ណាមួយទេ វិសោធន កម្មនោះត្រូវចូលជាធរមានក្នុងអំឡុងពេល ៩០ (កៅសិប)ថ្ងៃបន្ទាប់ សម្រាប់គ្រប់ភាគីជា សមាជិក លើកលែងតែភាគីណាដែលបានធ្វើ ខដាក់លក្ខខណ្ឌ ស្របតាមកថាខណ្ឌទី៣ នៃ មាត្រានេះ។

ឆ- ប្រសិនបើលេខាធិការដ្ឋានបានទទួលការជំទាស់ណាមួយ លេខាធិការដ្ឋានត្រូវដាក់ឲ្យបោះ ឆ្នោត តាមរយៈប្រៃសណីយ៍ ដោយអនុលោមតាមបញ្ញត្តិដូចមានចែងនៅក្នុងវាក្យខណ្ឌ (ជ) (ឈ) និង(ញ) នៃកថាខណ្ឌនេះ ។

ជ- លេខាធិការដ្ឋាន ត្រូវជូនដំណឹងទៅគ្រប់ភាគីជាសមាជិកទាំងអស់ថា បានទទួលការជំទាស់ នេះរួចហើយ ។

ឈ- លើកលែងតែលេខាធិការដ្ឋានបានទទួលសម្លេងគាំទ្រ ឬសម្លេងជំទាស់ ឬសម្លេងអនុប្បវាទ យ៉ាងតិច១/២ (មួយភាគពីរ) នៃភាគីជាសមាជិកទាំងអស់ក្នុងអំឡុងពេល ៦០(ហុកសិប)ថ្ងៃ

p

ចាប់ពីថ្ងៃជូនដំណឹងតាមវាក្យខណ្ឌ (ជ) នៃកថាខណ្ឌនេះ សេចក្តីស្នើសុំធ្វើវិសោធនកម្មត្រូវដាក់ជូនសន្និសីទជាសមាជិកលើកក្រោយដើម្បីពិចារណាបន្ថែម ។

ញ- ពេលទទួលបានសម្លេងឆ្នោតណាមានសម្លេងចំនួន១/២(មួយភាគពីរ) នៃភាគីជាសមាជិកទាំងអស់រួចហើយការធ្វើវិសោធនកម្មត្រូវអនុម័តយល់ព្រមដោយសម្លេង២/៣(ពីរភាគបី)នៃភាគីសមាជិកដែលអាចបោះឆ្នោតគាំទ្រ ឬជំទាស់។

ដ- លេខាធិការដ្ឋាន ត្រូវជូនដំណឹងដល់ភាគីជាសមាជិកទាំងអស់អំពីលទ្ធផលនៃការបោះឆ្នោត ។

ឋ- ប្រសិនបើសំណើសុំធ្វើវិសោធនកម្មត្រូវបានអនុម័តយល់ព្រមរួច ហើយវិសោធនកម្មនោះត្រូវចូលជាធរមានក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ ក្រោយពីថ្ងៃចេញសេចក្តីជូនដំណឹងដោយលេខាធិការដ្ឋានស្តីពីការទទួលស្គាល់លើវិសោធនកម្ម ដល់សមាជិកទាំងអស់ លើកលែងតែភាគីណាដែលបានធ្វើខដាក់លក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ។

៣- ក្នុងរយៈពេល ០៩ (កៅសិប)ថ្ងៃ ដូចដែលវាក្យខណ្ឌ (គ) នៃកថាខណ្ឌទី១ ឬវាក្យខណ្ឌ (ឋ) នៃកថាខណ្ឌទី២ នៃមាត្រានេះត្រូវបានផ្តល់ចំពោះភាគីមួយក្នុងរយៈពេលវេលា ៩០(កៅសិប)ថ្ងៃ ដោយជូនដំណឹងជាលាយល័ក្ខអក្សរទៅកាន់រដ្ឋាភិបាលតម្កល់ទុកឯកសារ អំពីការធ្វើខដាក់លក្ខខណ្ឌពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មនេះ។ ភាគីនេះ ត្រូវបានចាត់ទុកថាជារដ្ឋមិនមែនជាសមាជិករបស់អនុសញ្ញាទាក់ទងនឹងការធ្វើពាណិជ្ជកម្មលើប្រភេទដែលពាក់ព័ន្ធនោះ លុះត្រាតែ ខដាក់លក្ខខណ្ឌនេះត្រូវបានដកចេញទើបចាត់ទុកថាជារដ្ឋសមាជិកវិញ ។

មាត្រា ១៦
ការធ្វើវិសោធនកម្មឧបសម្ព័ន្ធ III

១- ភាគីជាសមាជិកនីមួយៗ អាចដាក់ជូនលេខាធិការដ្ឋានបានគ្រប់ពេលនូវបញ្ជីប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលខ្លួនវិនិច្ឆ័យឃើញថា គួរដាក់ឱ្យស្ថិតនៅក្រោមច្បាប់ ឬបទប្បញ្ញត្តិណាមួយនៃដែនសមត្ថកិច្ចរបស់ខ្លួន សម្រាប់គោលបំណងដូចបានបញ្ជាក់ក្នុងកថាខណ្ឌទី៣ នៃមាត្រា ២ ។ ឧបសម្ព័ន្ធ III ត្រូវបញ្ចូលឈ្មោះភាគីជាម្ចាស់លើប្រភេទស្នើសុំនោះភ្ជាប់ជាមួយ ដោយបញ្ជាក់ឈ្មោះវិទ្យាសាស្ត្រ និងផ្នែក ឬចំណែកដែលចេញពីសំណាកសត្វ ឬរុក្ខជាតិព្រៃពាក់ព័ន្ធទាំងនោះ ឱ្យបានសមស្របទៅតាមគោលបំណងដែលមានចែងក្នុងវាក្យខណ្ឌ (ខ) នៃមាត្រា ១ ។

p

២- ក្រោយពីបានទទួលបញ្ជីឈ្មោះប្រភេទសត្វ ឬរុក្ខជាតិព្រៃនីមួយៗ ដែលបានដាក់ជូនអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រានេះ លេខាធិការដ្ឋានត្រូវជូនដំណឹងដល់គ្រប់ភាគីជាសមាជិកទាំងអស់ឱ្យបានឆាប់បំផុត តាមដែលអាចធ្វើទៅបាន ។ បញ្ជីឈ្មោះនេះត្រូវចូលជាផ្នែកមួយរបស់ឧបសម្ព័ន្ធ III ក្នុងកំឡុងពេល ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានជូនដំណឹង ។ រាល់ទំនាក់ទំនងពាក់ព័ន្ធនឹងការកែប្រែបញ្ជីឈ្មោះ ភាគីនីមួយៗអាចធ្វើលិខិតជូនដំណឹងអំពីការធ្វើខដាក់លក្ខខណ្ឌចំពោះប្រភេទ ឬផ្នែក ឬបំណែកកែច្នៃជាលាយលក្ខអក្សរ ដាក់ជូនរដ្ឋាភិបាលតម្កល់ឯកសារ ។ រដ្ឋដែលបានធ្វើខ ដាក់លក្ខខណ្ឌត្រូវបានចាត់ទុកជាមិនមែនជាសមាជិកនៃអនុសញ្ញានេះ ចំពោះការធ្វើពាណិជ្ជកម្មលើប្រភេទ ផ្នែក ឬបំណែកកែច្នៃដែលពាក់ព័ន្ធនោះ រហូតដល់លក្ខខណ្ឌដែលដាក់ ត្រូវបានដក ទើបអាចចាត់ទុកជាជាសមាជិកវិញៗ

៣- ភាគីមួយដែលបានស្នើសុំដាក់បញ្ចូលប្រភេទសត្វ ឬរុក្ខជាតិទៅក្នុងឧបសម្ព័ន្ធ III អាចលើក សំណើដាក់ជូនទៅលេខាធិការដ្ឋាន ដើម្បីសុំដកចេញពីបញ្ជីវិញបាន ។ ការដកចេញនេះត្រូវចូលជាធរមានក្រោយអំឡុងពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានធ្វើការជូនដំណឹង ។

៤- ភាគីដែលស្នើសុំដាក់បញ្ចូលសំណាកនៃប្រភេទក្នុងបញ្ជីឈ្មោះ អនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវផ្ញើជូនលេខាធិការដ្ឋានរាល់អត្ថបទច្បាប់ ឬលិខិតបទដ្ឋាន ដែលពាក់ព័ន្ធដល់ការការពារប្រភេទនោះ ព្រមទាំងអត្ថបទបកស្រាយដែលភាគីនោះយល់ថាចាំបាច់ត្រូវផ្តល់ជូន ឬអាចមានតម្រូវការពីលេខាធិការដ្ឋាន ។ ក្នុងរយៈពេលដែលប្រភេទពាក់ព័ន្ធ ត្រូវបានបញ្ចូលក្នុងបញ្ជីឧបសម្ព័ន្ធ III ភាគីជាសមាជិកនេះត្រូវដាក់ជូនលេខាធិការដ្ឋាននូវការធ្វើវិសោធនកម្ម ការបកស្រាយនៃច្បាប់ និងលិខិតបទដ្ឋាននានា ដែលភាគីនេះបានអនុម័ត ។

មាត្រា ១៧
វិសោធនកម្មអនុសញ្ញា

១- កិច្ចប្រជុំវិសាមញ្ញមួយ នៃសន្និសីទរបស់ភាគីជាសមាជិកទាំងអស់ចំពោះការស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះ ត្រូវកោះប្រជុំដោយលេខាធិកាដ្ឋាន តាមការស្នើសុំជាលាយលក្ខអក្សរដោយភាគីជាសមាជិកចំនួន១/៣(មួយភាគបី) នៃភាគីទាំងអស់ៗ ការធ្វើវិសោធនកម្មណាមួយត្រូវអនុម័តយល់ព្រមដោយសម្លេង២/៣ (ពីរភាគបី) នៃចំនួនភាគីដែលមានវត្តមាន និងមានសិទ្ធិបោះ

ឆ្នោត ។ ក្នុងន័យនេះភាគីជាសមាជិកទាំងឡាយដែលមានវត្តមាន គឺជាភាគីដែលមានវត្តមាន និងមានសិទ្ធិធ្វើការបោះឆ្នោតគាំទ្រ ឬបដិសេធ ។ ភាគីដែលបោះឆ្នោតអនុប្បវាទមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនសរុប ២/៣ (ពីរភាគបី) សម្រាប់ការអនុវត្តលើវិសោធនកម្មនោះឡើយ ។

២- សេចក្តីស្នើសុំធ្វើវិសោធនកម្ម ត្រូវជូនដំណឹងទៅភាគីជាសមាជិកទាំងអស់តាមរយៈលេខាធិការដ្ឋានឱ្យបានមុនរយៈពេល ៩០ (កៅសិប)ថ្ងៃនៃថ្ងៃបើកកិច្ចប្រជុំ ។

៣- វិសោធនកម្មចូលជាធរមានសម្រាប់គ្រប់ភាគី ដែលបានអនុម័តយល់ព្រមនៅក្រោយអំឡុងពេល ៦០ (ហុកសិប)ថ្ងៃ បន្ទាប់ពីចំនួន ២/៣ (ពីរភាគបី) នៃភាគីជាសមាជិកទាំងនោះដាក់លិខិតូបករណ៍ទទួលស្គាល់វិសោធនកម្មជូនរដ្ឋាភិបាលតម្កល់ឯកសារ ។ បន្ទាប់មក វិសោធនកម្មត្រូវចូលជាធរមានសម្រាប់ភាគីផ្សេងទៀត ក្រោយរយៈពេល៦០(ហុកសិប) ថ្ងៃបន្ទាប់ពីថ្ងៃ ដែលភាគីទាំងនោះបានដាក់ជូនលិខិតូបករណ៍ទទួលស្គាល់វិសោធនកម្ម ជូនរដ្ឋាភិបាលតម្កល់ឯកសារ ។

មាត្រា ១៨
ការដោះស្រាយវិវាទ

១- រាល់វិវាទដែលអាចកើតឡើងរវាងភាគីជាសមាជិកពីរ ឬច្រើនទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះត្រូវធ្វើតាមរយៈការចរចាររវាងភាគីដែលពាក់ព័ន្ធនឹងវិវាទនោះ ។

២- បើវិវាទមិនអាចដោះស្រាយតាមការចរចារគ្នា ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះទេ ភាគីដោយព្រមព្រៀងគ្នាទាំងនោះអាចដាក់ជូនស្ថាប័នអាជ្ញាកណ្តាលជាពិសេសទៅកាន់តុលាការនៅទីក្រុងឡាអេ ដើម្បីធ្វើការវិនិច្ឆ័យ ហើយភាគីវិវាទត្រូវគោរពតាមសេចក្តីសម្រេចរបស់តុលាការនេះ ។

មាត្រា ១៩
ការចុះហត្ថលេខា

អនុសញ្ញានេះត្រូវបានបើកឲ្យធ្វើការចុះហត្ថលេខានៅរដ្ឋធានីវ៉ាស៊ីនតោន រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៣ និងបន្ទាប់មកត្រូវបានបើកឲ្យធ្វើការចុះហត្ថលេខានៅទីក្រុងបេន រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ ។

មាត្រា ២០
ការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម

អនុសញ្ញានេះត្រូវមានការផ្តល់សច្ចាប័ន ទទួលស្គាល់ ឬយល់ព្រម ។ ឯកសារផ្លូវការនៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការយល់ព្រមត្រូវបញ្ជូនទៅតម្កល់ទុកនៅរដ្ឋាភិបាលសហព័ន្ធស្វីស ដែលជារដ្ឋាភិបាលតម្កល់ឯកសារ ។

មាត្រា ២១
ការសុំចូលជាសមាជិក

អនុសញ្ញានេះត្រូវបានបើកចំហរដោយគ្មានកំណត់ចំពោះការសុំចូលជាសមាជិក ។ ឯកសារផ្លូវការនៃការសុំចូលជាសមាជិក ត្រូវបានយកទៅតម្កល់ទុកនៅរដ្ឋាភិបាលតម្កល់ឯកសារ ។

មាត្រា ២២
ការចូលជាធរមាន

១- អនុសញ្ញានេះត្រូវចូលជាធរមាន ៩០ (កៅសិប)ថ្ងៃបន្ទាប់ពីបានតម្កល់ឯកសារផ្លូវការទី១០ នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិកនៅរដ្ឋាភិបាលតម្កល់ឯកសារ ។

២- ចំពោះរដ្ឋ ដែលធ្វើការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការយល់ព្រមអនុសញ្ញានេះ ឬការសុំចូលជាសមាជិកនៅក្រោយពេលដែលឯកសារទី១០ ត្រូវបានតម្កល់រួច អនុសញ្ញានេះនឹងត្រូវចូលជាធរមាន ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីរដ្ឋនេះ បានតម្កល់ឯកសារស្តីពីការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិករបស់ខ្លួន ។

មាត្រា ២៣
ការទទួលយកអនុសញ្ញាដោយការធ្វើ ជាក់លក្ខខណ្ឌ

p

១- បទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះមិនអាចត្រូវធ្វើជាលក្ខខណ្ឌជាទូទៅទាំងនោះបានទេ ។ លក្ខខណ្ឌជាក់លាក់ អាចត្រូវបានធ្វើជាខដាក់លក្ខខណ្ឌដោយអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា នេះមាត្រា១៥ និងមាត្រា ១៦ ។

២- នៅពេលតម្កល់ឯកសារផ្តល់សច្ចាប័ន ឯកសារទទួលស្គាល់ ឯកសារយល់ព្រម ឬឯកសារសុំចូលជាសមាជិក រដ្ឋនីមួយៗអាចបញ្ចូលឯកសារធ្វើខ ដាក់លក្ខខណ្ឌបានទាក់ទងនឹង ៖

ក- ប្រភេទណាមួយនៅក្នុងឧបសម្ព័ន្ធ I, II និង III ។

ខ-ផ្នែកឬបំណែកកែច្នៃណាមួយដែលបញ្ជាក់បានច្បាស់លាស់ពាក់ព័ន្ធជាមួយប្រភេទក្នុងឧបសម្ព័ន្ធ III ។

៣- ទាល់តែមានការដកចេញនូវលិខិតធ្វើខ ដាក់លក្ខខណ្ឌរបស់ខ្លួនដែលមានក្នុងមាត្រានេះ ភាគីនោះត្រូវបានចាត់ទុកថា ជាភាគីមិនមែនជាសមាជិកនៃអនុសញ្ញានេះទេ ទាក់ទងនឹងការធ្វើពាណិជ្ជកម្មប្រភេទ ជាពិសេសផ្នែក ឬបំណែកកែច្នៃ ដែលមានចែងក្នុងឯកសារធ្វើខ ដាក់លក្ខខណ្ឌនោះ។

មាត្រា ២៤
ការសុំលាលែងចេញពីសមាជិកភាព

ភាគីនីមួយៗអាចលាលែងចេញពីសមាជិកភាពនៃអនុសញ្ញានេះ ដោយការធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរដាក់ជូនរដ្ឋាភិបាលតម្កល់ឯកសារបានគ្រប់ពេល ។ សេចក្តីសុំលាលែងចេញពីសមាជិកភាពត្រូវមានប្រសិទ្ធភាព នៅក្រោយរយៈពេល ១២ (ដប់ពីរ)ខែ បន្ទាប់ពីរដ្ឋាភិបាលតម្កល់ឯកសារ បានទទួលសេចក្តីជូនដំណឹងនេះ ។

មាត្រា ២៥
ការតម្កល់ឯកសារ

១- អនុសញ្ញានេះមានអត្ថបទដើមសរសេរជា ភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងភាសាអេស្ប៉ាញ ដែលមានខ្លឹមសារ និងតម្លៃស្មើគ្នា និងត្រូវបានតម្កល់ទុកនៅរដ្ឋាភិបាលតម្កល់ឯកសារ ដែលត្រូវបញ្ជូនជាអត្ថបទចម្លងទៅគ្រប់ភាគីជាសមាជិកទាំងអស់ដែលបានចុះហត្ថលេខា ឬដែលបានតម្កល់ឯកសារផ្លូវការរបស់ខ្លួន ដើម្បីស្នើសុំចូលជាសមាជិក ។

p

២- រដ្ឋាភិបាលតម្កល់ឯកសារត្រូវជូនដំណឹងដល់បណ្តារដ្ឋហត្ថលេខី និងរដ្ឋសូមចូលជាសមាជិកទាំងអស់នៃអនុសញ្ញា និងលេខាធិការដ្ឋាន អំពីការចុះហត្ថលេខា ការតម្កល់ឯកសារផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិក ការចូលជាធរមានរបស់អនុសញ្ញាធ្វើវិសោធនកម្ម ការសុំបញ្ចូល និងការសុំដកឯកសារធ្វើខ ដាក់លក្ខខណ្ឌ និងការសុំលាលែងចេញពីសមាជិកភាពទាំងអស់ ។

៣- នៅពេលអនុសញ្ញានេះ ចូលជាធរមានភ្លាម ឯកសារចម្លងមានបញ្ជាក់ថាត្រឹមត្រូវមួយ ត្រូវបានបញ្ជូនដោយរដ្ឋាភិបាលតម្កល់ឯកសារទៅកាន់លេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ដើម្បីធ្វើការចុះបញ្ជី និងការផ្សព្វផ្សាយអនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

ដើម្បីទុកជាសក្ខីភាព ហត្ថលេខីពេញសមត្ថភាពទាំងឡាយ ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវខាងក្រោម បានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅរដ្ឋធានីវ៉ាស៊ីនតោន នាថ្ងៃទី៣ (បី) ខែមីនា ឆ្នាំ១៩៧៣ (មួយពាន់ប្រាំបួនរយចិតសិបបី) ។

p

KINGDOM OF CAMBODIA
Nation Religion King

CONVENTION ON INTERNATIONAL TRADE IN ENDANGERED SPECIES OF WILD FAUNA AND FLORA

លិខិតអនុញ្ញាត សាយធេស
CITES PERMIT / CERTIFICATE

No.

☐ EXPORT នាំចេញ	☐ RE-EXPORT នាំចេញបន្ត	☐ IMPORT នាំចូល	☐ OTHER: ផ្សេងៗ	2. Valid until មានតំលៃរហូត

3. Importer (name and address) អ្នកនាំចូល "ឈ្មោះ និង អាសយដ្ឋាន"	4. Exporter (name and address, country) អ្នកនាំចេញ "ឈ្មោះ អាសយដ្ឋាន និង ប្រទេស"
3a. Country of import ប្រទេសនាំចូល	
5. Special conditions លក្ខខណ្ឌពិសេស For live animals, this permit or certificate is only valid if the transport conditions conform to the Guidelines for Transport of live Animals or, in the case of air transport, to the IATA Live Animals Regulations សំរាប់សត្វរស់ លិខិតអនុញ្ញាតនេះមានតំលៃលុះត្រាតែលក្ខខណ្ឌនៃការដឹកនាំស្របទៅតាមគោលការណ៍ណែនាំនៃការដឹកជញ្ជូនសត្វរស់ ឬក្នុងករណីនៃការដឹកនាំតាមផ្លូវអាកាសស្របទៅនឹងគោលការណ៍ណែនាំសត្វរស់របស់ IATA	6. Name, address, national seal/stamp and country of Management Authority ឈ្មោះ អាសយដ្ឋាន ត្រាសម្គាល់ ត្រាជាតិ និង ប្រទេសរបស់អាជ្ញាធរគ្រប់គ្រង Ministry of Agriculture Forestry and Fisheries. Cambodian CITES Management Authority 200, Norodom Blvd, Phnom Penh Cambodia
5a. Purpose of the transaction គោលបំណងនៃការនាំចេញ	5b. Security stamp N° លេខត្រា	

	7/8. SCIENTIFIC NAME (genus and species) AND COMMON NAME OF ANIMAL OR PLANT ឈ្មោះវិទ្យាសាស្ត្រ "ពួក និង ប្រភេទ" និង ឈ្មោះធម្មតារបស់សត្វ ឬរុក្ខជាតិ	9. Description of specimens including identifying marks or numbers (age/sex if live) បរិយាយប្រភេទគំរូ បង្ហាញសំគាល់ "ចំនួន អាយុ / ភេទ បើរស់នៅ"	10. Appendix No. and source លេខឧបសម្ព័ន្ធ និង ប្រភព	11. Quantity (including Unit) បរិមាណ "រួមទាំងឯកតា"	11a. Total exported/Quota ចំនួននាំចេញសរុប / កូតា
A					
B					
C					

12. Country of origin ប្រទេសដើម	Permit No លេខលិខិតអនុញ្ញាត	Date កាលបរិច្ឆេទ	12a. Country of last re-export ប្រទេសនាំចេញចុងក្រោយ	Certificate No. លេខលិខិតអនុញ្ញាត	Date កាលបរិច្ឆេទ	12b. No. of the operation or date of acquisition លេខប្រតិបត្តិ ឬ កាលបរិច្ឆេទដែលបានទទួល

13. THIS PERMIT IS ISSUED BY
លិខិតអនុញ្ញាតនេះចេញដោយ

Place ទីកន្លែង ____ Date កាលបរិច្ឆេទ ____ Security stamp signature official seal លេខត្រា ហត្ថលេខានិងត្រាផ្លូវការ ____

14. EXPORT ENDORSEMENT
កំណត់បញ្ជីនាំចេញ

Bill of Lading/Air waybill Number
បញ្ជីឈ្មោះទំនិញដឹកនាំ / ចំនួនលិខិតដឹកជញ្ជូនតាមយន្តហោះ

Block ប្លុក	Quantity បរិមាណ
A	
B	
C	

Port of Export ច្រកនាំចេញ ____ Date កាលបរិច្ឆេទ ____ Signature ហត្ថលេខា ____ Official stamp and title ត្រាផ្លូវការនិងឈ្មោះ ____

Original No.

p

Instructions and explanation

(The [illegible]orrespond to block numbers on the form)

1. Tick the square, which corresponds to the type of document issued (export permit, re-export certificate, import permit or other). If the square "other" has been ticked, the type of document must be indicated. The original number is a unique number allocated to each document by the Management Authority.

2. For export permits and re-export certificates, the date of expiry of the document may not be more than six months after the date of issuance [illegible]

3. Complete name and address of the importer

 3a. The name of the country must be written in full

4. Complete name and address of the exporter. The name of the country must be stated. The absence of the signature of the applicant renders the permit or certificate invalid

២២៧	លោក ភេម មន្នី	សិក្ខាបនធារី	សាលាបឋមសិក្សា គោកព្នៅ	ស្រុកពួក
២២៨	លោក គឹក ឈៅ	សិក្ខាបនធារី	សាលាបឋមសិក្សា ស្វាហួល	ស្រុកពួក
២២៩	លោក មក់ សុង	សិក្ខាបនធារី	សាលាបឋមសិក្សា ព្រៃជ្រូក	ស្រុកពួក
២៣០	លោក ង៉ាម គង់	សិក្ខាបនធារី	សាលាបឋមសិក្សា ប្រាសាទ	ស្រុកពួក
២៣១	លោក មិញ ស៊ីសុវណ្ណ	សិក្ខាបនធារី	សាលាបឋមសិក្សា ប្រាសាទ	ស្រុកពួក
២៣១	លោក គាត សុខ	សិក្ខាបនធារី	សាលាបឋមសិក្សា ច្រនៀង	ស្រុកពួក
២៣៣	លោក អ៊ាន ស៊ង់	សិក្ខាបនធារី	សាលាបឋមសិក្សា ប្រដាក់	ស្រុកពួក
២៣៤	លោក ទិត្យ សារ៉ាត់	សិក្ខាបនធារី	សាលាបឋមសិក្សា ស្វាយ	ស្រុកពួក
២៣៥	លោក ខ្សែម ឌុល	សិក្ខាបនធារី	សាលាបឋមសិក្សា ធ្វាស	ស្រុកពួក
២៣៦	លោក ផាត ឌី	សិក្ខាបនធារី	សាលាបឋមសិក្សា គោកខ្លាំង	ស្រុកពួក
២៣៧	លោកស្រី សុង សឿយ	សិក្ខាបនធារី	សាលាបឋមសិក្សា ភូមិស្វាយ	ស្រុកពួក
២៣៨	លោក សំ សុផាត	សិក្ខាបនធារី	សាលាបឋមសិក្សា ក្រឡាញ់	ស្រុកក្រឡាញ់
២៣៩	លោក ឌូន សុផា	សិក្ខាបនធារី	សាលាបឋមសិក្សា ក្រឡាញ់	ស្រុកក្រឡាញ់
២៤០	លោក យ៉ែម សូភិត	សិក្ខាបនធារី	សាលាបឋមសិក្សា កំពង់ថ្កូវ	ស្រុកក្រឡាញ់
២៤១	លោក ព្រាប សារឿន	សិក្ខាបនធារី	សាលាបឋមសិក្សា កំពង់ថ្កូវ	ស្រុកក្រឡាញ់
២៤២	លោក ហេង ហ៊ុន	សិក្ខាបនធារី	សាលាបឋមសិក្សា កំពង់ថ្កូវ	ស្រុកក្រឡាញ់
២៤៣	លោក ម៉ៅ ង៉ិក	សិក្ខាបនធារី	សាលាបឋមសិក្សា កំពង់ថ្កូវ	ស្រុកក្រឡាញ់
២៤៤	លោក សំ ទី	សិក្ខាបនធារី	សាលាបឋមសិក្សា ទន្លេសរ	ស្រុកអង្គរជុំ
២៤៥	លោកស្រី ស៊ុំ ចន្ថា	សិក្ខាបនធារី	សាលាបឋមសិក្សា ស្រែខ្វាវ	ស្រុកអង្គរជុំ
២៤៦	លោក ឈើយ ជួង	សិក្ខាបនធារី	សាលាបឋមសិក្សា បេង	ស្រុកអង្គរជុំ
២៤៧	លោក លាត សេម	សិក្ខាបនធារី	សាលាបឋមសិក្សា គោកព្នៅ	ស្រុកអង្គរជុំ
២៤៨	លោកស្រី សេង បាន	សិក្ខាបនធារី	សាលាបឋមសិក្សា គ្រួសារយោធាការ	ស្រុកអង្គរជុំ
២៤៩	លោក សារុន សំអ៊ាង	សិក្ខាបនធារី	សាលាបឋមសិក្សា គ្រីស្តហ្ស៊័របោវ	ស្រុកអង្គរជុំ
២៥០	លោកស្រី សាយ ស៊ីដា	សិក្ខាបនធារី	សាលាបឋមសិក្សា បុស្សល្វង	ស្រុកអង្គរជុំ
២៥១	លោក សួន ប៊ុនស៊ី	សិក្ខាបនធារី	សាលាបឋមសិក្សា កំប្លើប	ស្រុកអង្គរជុំ
២៥២	លោក វត្ថ ប៊ុនហ៊ាត	សិក្ខាបនធារី	វិទ្យាល័យ អង្គរជុំ	ស្រុកអង្គរជុំ

p

២៥៣	លោក វិន សុធី	សិក្ខាបនធារី	វិទ្យាល័យ ២៨មករា	ស្រុកស្រីស្នំ
២៥៤	លោកស្រី ធិញ វុដ្ឋា	សិក្ខាបនធារី	វិទ្យាល័យ ២៨មករា	ស្រុកស្រីស្នំ
២៥៥	លោក អ៊ិត វៅ	សិក្ខាបនធារី	វិទ្យាល័យ ២៨ មករា	ស្រុកស្រីស្នំ
២៥៦	លោកស្រី ធិញ សាភាយ	សិក្ខាបនធារី	សាលាបឋមសិក្សា រំដេង	ស្រុកស្រីស្នំ
២៥៧	លោកស្រី ម៉ៅ សួត	សិក្ខាបនធារី	សាលាបឋមសិក្សា រំដេង	ស្រុកស្រីស្នំ
២៥៨	លោកស្រី អៀន សំណាង	សិក្ខាបនធារី	សាលាបឋមសិក្សា ពង្រ	ស្រុកស្រីស្នំ
២៥៩	លោកស្រី ផុន រ៉ាវី	សិក្ខាបនធារី	សាលាបឋមសិក្សា ជូនសុខ	ស្រុកស្រីស្នំ
២៦០	លោកស្រី ដោក រាត្រា	សិក្ខាបនធារី	សាលាបឋមសិក្សា សាលា	ស្រុកស្រីស្នំ
២៦១	លោកស្រី លឹម សុផាត់	សិក្ខាបនធារី	សាលាបឋមសិក្សា ខ្ញែក	ស្រុកស្រីស្នំ
២៦២	លោក រីក ចំរើន	សិក្ខាបនធារី	សាលាបឋមសិក្សា ឬស្សីតូច	ស្រុកវ៉ារិន
២៦៣	លោក ធី វិបុល	សិក្ខាបនធារី	សាលាបឋមសិក្សា កំបោរ	ស្រុកវ៉ារិន
២៦៤	លោក គន់ ពាយ	សិក្ខាបនធារី	សាលាបឋមសិក្សា ប្រាសាទ	ស្រុកវ៉ារិន
២៦៥	លោក ឌីប នឿន	សិក្ខាបនធារី	សាលាបឋមសិក្សា កញ្ចន់រុន	ស្រុកវ៉ារិន
២៦៦	លោក គុំ ម្និះ	សិក្ខាបនធារី	អនុវិទ្យាល័យ ខ្នារសណ្តាយ	ស្រុកបន្ទាយស្រី
២៦៧	លោកស្រី ហៀប សារ៉ម	សិក្ខាបនធារី	សាលាបឋមសិក្សា ត្បែង	ស្រុកបន្ទាយស្រី
២៦៨	លោក តាន់ ប៊ុនហួយ	សិក្ខាបនធារី	សាលាបឋមសិក្សា បន្ទាយសំរែ	ស្រុកបន្ទាយស្រី
២៦៩	លោក ឆោម ភីរដ្ឋ	សិក្ខាបនធារី	វិទ្យាល័យ បន្ទាយស្រី	ស្រុកបន្ទាយស្រី
២៧០	លោកស្រី ម៉ៅ សុខុន	សិក្ខាបនធារី	សាលាបឋមសិក្សា តាត្រាវ	ស្រុកអង្គរធំ
២៧១	លោកស្រី ម៉ាប់ ស្រីភុំ	សិក្ខាបនធារី	សាលាបឋមសិក្សា សណ្តាន់	ស្រុកអង្គរធំ
២៧២	លោក ហុង ហម	សិក្ខាបនធារី	សាលាបឋមសិក្សា តាត្រាវ	ស្រុកអង្គរធំ
២៧៣	លោកស្រី ឡូ ម៉ៅ	សិក្ខាបនធារី	សាលាបឋមសិក្សា របាល	ស្រុកស្វាយលើ
២៧៤	លោកស្រី ភឿន សុខា	សិក្ខាបនធារី	សាលាបឋមសិក្សា ហ៊ុនសែនស្វាយលើ	ស្រុកស្វាយលើ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាបត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១..

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តរតនគិរី ចំនួន ៨៣រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក.មេដាយមាសការងារ

១	លោក	ប៉ា	សត្ថា	អនុប្រធាន	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
២	លោកស្រី	ថា	ចាន់ថន	នាយិកា	អនុវិទ្យាល័យឡាបានសៀក	ស្រុកបានលុង
៣	លោក	យ៉ែម	យេង	នាយក	សាលាបឋម អេហ្សាព៍រ៉ូហ្គែល	ស្រុកបានលុង
៤	លោក	ឡុក	ចិន	គ្រូ.កម្រិតបឋម	សាលាបឋមជ័យឧត្តម	ស្រុកលំផាត់
៥	លោក	មាស	ចុង	គ្រូ.កម្រិតមូលដ្ឋាន	វិទ្យាល័យហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
៦	លោកស្រី	ស៊ុំ	ថាវី	គ្រូ.កម្រិតបឋម	សាលាបឋម.បុរីកម្មករ ២	ស្រុកបានលុង
៧	លោកស្រី	សៀ	សុផាច	គ្រូ.កម្រិតបឋម	សាលាបឋមបុរីកម្មករ២	ស្រុកបានលុង
៨	លោក	សួន	កុសល្យ	គ្រូ.កម្រិតមូលដ្ឋាន	វិ. សម្តេចឪ សម្តេចម៉ែ	ស្រុកបានលុង
៩	លោក	អ៊ុង	គីមស្រេង	គ្រូ.កម្រិតបឋម	បឋម ឡាបានសៀក	ស្រុកបានលុង

ខ.មេដាយប្រាក់ការងារ

១	លោក	ស៊ូ	មករា	អនុប្រធានការិ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី

p

២	លោក	អ៊ិន	ណៃមណ្ណារិទ្ធ	អនុប្រធានការិ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
៣	លោក	សេស	រិន	អនុប្រធានការិ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
៤	លោក	ជឿន	រក្សា	អនុប្រធានការិ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
៥	លោក	កន	សារ៉ែន	មន្ត្រីក្រមការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
៦	លោកស្រី	ចិន	គីមលេន	មន្ត្រីក្រមការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
៧	លោក	ទៀង	ភីភក្តិ	មន្ត្រីគ្រប់គ្រងរដ្ឋបាល	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
៨	លោក	ចាន់	វាសនា	មន្ត្រីក្រមការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
៩	លោក	លើយ	សុទ្ធ	មន្ត្រីក្រមការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
១០	លោកស្រី	អ៊ុំ	សំអឿន	មន្ត្រីក្រមការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
១១	លោក	សេង	សុវណ្ណរតន៍	លេខាធិការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
១២	លោកស្រី	សុខ	សឿន	លេខាធិការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
១៣	លោក	មៀច	ឈិន	ប្រធាន	ការិ.អប់រំ យុវជន និកីឡា	ស្រុកបរកែវ
១៤	លោក	ទុំ	ច្រិន	អនុប្រធាន	ការិ.អប់រំ យុវជន និកីឡា	ស្រុកបរកែវ
១៥	លោក	ជឿន	ជំរឿន	គ្រូ.កម្រិតមូលដ្ឋាន	វិ.សម្តេចឪ សម្តេចម៉ែ	ស្រុកបានលុង
១៦	លោក	ស៊ាង	ចន្ថា	នាយក	អនុវិ.គ្រពាំងក្រហម	ស្រុកកូនមុំ
១៧	លោក	ម៉ិល	សារេត	នាយក	សាលាបឋម បុរីកម្មករ១	ស្រុកបានលុង
១៨	លោក	គួច	សុខ	ភ្នាក់ងាររដ្ឋបាល	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគីរី
១៩	លោក	ឆន	ការី	នាយក	អនុវិ.អណ្តូងមាស	ស្រុកអណ្តូងមាស
២០	លោកស្រី	ម៉ម	ស៊ីថេន	នាយិកា	បឋម.រលើយួន	ស្រុកបានលុង
២១	លោកស្រី	យឹម	ធារី	គ្រូ.កម្រិតមូលដ្ឋាន	អនុវិ.សោមធំ	ស្រុកអូរយ៉ាដាវ
២២	លោក	នាក់	ប៊ុនធឿន	នាយក	បឋមកាតៃ	ស្រុកអូរយ៉ាដាវ
២៣	លោក	ណុប	គន្ធា	គ្រូ.កម្រិតមូលដ្ឋាន	វិ.សម្តេចឪ សម្តេចម៉ែ	ស្រុកបានលុង
២៤	លោកស្រី	ប៉ិល	សុការី	គ្រូ.កម្រិតមូលដ្ឋាន	វិ.ហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
២៥	លោកស្រី	ជ័យ	វ៉ាន់	គ្រូ.កម្រិតបឋម	បឋម ឡាបានសៀក	ស្រុកបានលុង
២៦	លោក	សោម	សំអាន	នាយក	បឋមជ័យឧត្តម	ស្រុកលំផាត់
២៧	លោក	កែវ	វណ្ណា	នាយករង	បឋម ហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
២៨	លោក	ឯម	ស៊ីដូ	នាយក	បឋមអូរសៀងលែ	ស្រុកលំផាត់
២៩	លោក	ប៊ុន	ចាន់ស៊ីហា	គ្រូ.កម្រិតបឋម	បឋម តាឡាវ	ស្រុកអណ្តូងមាស
៣០	លោកស្រី	សា	សុធា	គ្រូ.កម្រិតមូលដ្ឋាន	វិ.សម្តេចឪ សម្តេចម៉ែ	ស្រុកបានលុង
៣១	លោក	គង់	សុខ	គ្រូ.កម្រិតបឋម	បឋម.បុរីកម្មករ ៣	ស្រុកបានលុង
៣២	លោកស្រី	ជួ	គីមស៊ីន	គ្រូ.កម្រិតបឋម	បឋម សម្តេចក្រុមព្រះ	ស្រុកបានលុង

៣៣	លោក	ហោ	ម៉េងឡាយ	នាយក	អនុវិ.អូរជុំ	ស្រុកអូរជុំ
៣៤	លោក	យូសុះ	អាប់ឌុលការីម	គ្រូ.កម្រិតមូលដ្ឋាន	អនុ.អន្លោភសិកដ្ឋាន	ស្រុកបានលុង
៣៥	លោក	តែម	សិត	នាយករង	បបម.ហ៊ុនសែនយក្ខឡោម	ស្រុកបានលុង

គ.មេដាយសំរឹទ្ធការងារ

១	លោក	ចាន់	ថេត	ប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
២	លោក	វណ្ណ	វុធ	ប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
៣	លោក	ស៊ុក	ប៊ុន្ថា	ប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
៤	លោក	ឡុត	ផល្លា	អនុប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
៥	លោក	ង៉ែត	ប៊ុណ្ណា	អនុប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
៦	លោក	ជាន់	សុភ័ក្រយុទ្ធ	អនុប្រធានការិយាល័យ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
៧	លោកស្រី	សៀន	រក្សា	នាយិការង	វិ.សម្តេចឪ សម្តេចម៉ែ	ស្រុកបានលុង
៨	លោក	គាក់	ស៊ីថេត	នាយករង	វិ.ហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
៩	លោកស្រី	ជួន	សំណាង	នាយករង	អនុវិ.ឡាបានសៀក	ស្រុកបានលុង
១០	លោក	អ៊ឹម	ត្សូ	ក្រមការ	ការិ.អយកក្រុង	ស្រុកបានលុង
១១	លោក	ឡុង	សុវណ្ណគិរី	លេខាធិការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
១២	លោកស្រី	សុំ	ច័ន្ទថាវន	លេខាធិការ	មន្ទីរអប់រំ យុវជន និកីឡា	ខេត្តរតនគិរី
១៣	លោកស្រី	ហុង	ដាវី	ក្រមការ	វិ.ហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
១៤	លោក	ង៉ែត	សុភេន	នាយករង	អនុវិ.ត្រពាំងច្រេស	ស្រុកកូនមុំ
១៥	លោកស្រី	លំ	សោភា	គ្រូ.កម្រិតបឋម	បឋម យក្ខឡោម	ស្រុកបានលុង
១៦	លោក	ប៊ុត	សំបូរ	គ្រូ.កម្រិតបឋម	បឋម ហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
១៧	លោកស្រី	កែវ	សោភ័ណ្ឌ	គ្រូ.កម្រិតបឋម	បឋមឡាបានសៀក	ស្រុកបានលុង
១៨	លោក	ញឹម	សិ	គ្រូ.កម្រិតឧត្តម	វិ.ហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
១៩	លោក	ចួន	ញ៉ាង	នាយក	បឋម កាឡែង	ស្រុកលំផាត់
២០	លោក	នឹម	ពលៈ	សិក្ខាបនធារី	បឋមអូរសៀងលៃ	ស្រុកលំផាត
២១	លោកស្រី	ភោគ	ភារម្យ	សិក្ខាបនធារី	បឋម កាតៃ	ស្រុកអណ្តូងមាស
២២	លោក	ថេន	ប៊ុនទាង	លេខាធិការ	ការិ.អយកអូរយ៉ាដាវ	ស្រុកអូរយ៉ាដាវ
២៣	លោក	កែវ	ស៊ីថា	សិក្ខាបនធារី	បឋម អណ្តូងមាស	ស្រុកអណ្តូងមាស
២៤	លោកស្រី	ប៊ុន	ចាន់ស៊ី	គ្រូ.កម្រិតបឋម	បឋមជ័យឧត្តម	ស្រុកលំផាត
២៥	លោក	មៅ	សំអាត	គ្រូ.កម្រិតមូលដ្ឋាន	អនុវិ.អណ្តូងមាស	ស្រុកអណ្តូងមាស
២៦	លោក	តាំង	សុភា	នាយក	វិ.ត្រពាំងក្រហម	ស្រុកកូនមុំ
២៧	លោក	ចាន់	ណារឿន	នាយក	អនុវិ.តាវែង	ស្រុកតាវែង

p

២៨	លោក	យុន	វុទ្ធី	នាយក	បឋម ហ៊ុនសែនតាវែង	ស្រុកតាវែង
២៩	លោក	ស៊ាង	ប៊ុណ្ណារ៉ូ	នាយក	អនុវិ.អូរយ៉ាដាវ	ស្រុកអូរយ៉ាដាវ
៣០	លោក	ជាង	ជូន	នាយក	បឋម.កាំបាក់	ស្រុកកូនមុំ
៣១	លោកស្រី	ស៊ូ	កល្យា	សិក្ខាបនធារី	បឋម.តាតៃ	ស្រុកអណ្តូងមាស
៣២	លោក	យ៉ែម	វិចិត្រ	នាយក	បឋម.វ៉ឺនសៃ	ស្រុកវ៉ឺនសៃ
៣៣	លោក	ស៊ី	សៅរិទ្ធិ	គ្រូ.កម្រិតបឋម	បឋម.ត្រុំ	ស្រុកបរកែវ
៣៤	លោក	សៅ	ម៉ន	គ្រូ.កម្រិតបឋម	បឋម.ឯកភាព	ស្រុកអុរជុំ
៣៥	លោក	ស	ប៊ុនរស្មី	គ្រូ.កម្រិតបឋម	បឋមភូមិជ្រៃ	ស្រុកបានលុង
៣៦	លោក	សំ	រៀន	នាយក	បឋម ប៉ក់ធំ	ស្រុកអូរយ៉ាដាវ
៣៧	លោកស្រី	សុខ	សុគន្ធា	គ្រូ.កម្រិតបឋម	បឋម អណ្តូងមាស	ស្រុកអណ្តូងមាស
៣៨	លោកស្រី	សេន	ចាន់រដ្ឋ	គ្រូ.កម្រិតបឋម	បឋម ហ៊ុនសែនភូមិថ្មី	ស្រុកបានលុង
៣៩	លោក	ចាន់	ភាសនា	គ្រូ.កម្រិតបឋម	បឋម.ភូមិថ្មី	ស្រុកវ៉ឺនសៃ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុងស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៧៣ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សា ខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញសម្រាប់អាណត្តិទី១
- បានឃើញសេចក្តីសម្រេចលេខ ២៦២/១១ គ.ជ.ប.សសរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១-	លោក **គ្រួច ផាន**	ជាប្រធានក្រុមប្រឹក្សាខណ្ឌ
២-	លោក **សាន ស៊ីផាន់**	ជាសមាជិកក្រុមប្រឹក្សាខណ្ឌ

p

៣- លោក **ស៊ុម គុំ** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
៤- លោក **ឈឿក ខែម** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
៥- លោក **ម៉ុន ច័ន្ទ** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
៦- លោក **ហ៊ី សាយ** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
៧- លោកស្រី **អ៊ឹម ថាវី** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
៨- លោក **ហែម សម្បត្តិ** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
៩- លោក **ម៉ុល ផាន់** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១០- លោក **សូ យុត្តា** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១១- លោក **គាង សារ៉ឿន** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១២- លោក **ជួន ទីចិត្រ** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១៣- លោក **ម៉ុំ មាន** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១៤- លោក **លឹម ឡៅ** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១៥- លោក **ជួប សុខហេង** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១៦- លោក **ម៉ែន ឈឿន** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១៧- លោក **ហែម សម្បត្តិ** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១៨- លោក **ហេង ច័ន្ទសុទ្ធី** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ
១៩- លោក **ស្វាយ ចាយគេង** ជាសមាជិកក្រុមប្រឹក្សាខណ្ឌ ។

មាត្រា ២ : ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៣ : ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ ត្រូវអនុវត្តតាម រដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៨០អនក្រ.បក ចុះថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០១១ ស្តីពីការបង្កើតខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ចលោក **គិត សុផា** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១០ ពីអភិបាលខណ្ឌដង្កោ ទៅជាអភិបាលខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ ។

មាត្រា ២ : ត្រូវបានតែងតាំងលោក **នុត ពុធដារ៉ា** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៩ ជាអភិបាលខណ្ឌដង្កោ នៃរាជធានីភ្នំពេញ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ[illegible] ឆ្នាំ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

ក្រសួងព្រះបរមរាជវាំង
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៤៨ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរបញ្ចូលលោក **ជា ពិសី** ទៅក្នុងឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
  ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៤៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឡាវ់ ស៊ីហារ៉ា** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៤ ជា**អភិបាលរង** នៃគណៈអភិបាលខេត្តព្រះសីហនុ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
  រាជកិច្ច
- ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៥០ . អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនវិស្វករ ចំនួន០២រូប ដែលមានស្នាដៃល្អខិតខំប្រឹងប្រែងចូលរួមចំណែកសាងសង់ស្ពានអាកាសស្តុបពេទ្យលោកសង្ឃ ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

១-លោក	ជិន	មុត	វិស្វករសាងសង់ស្ពានរបស់ក្រុមហ៊ុន OCIC
២-លោក	ម៉េង	ចំរើន	វិស្វករសាងសង់ស្ពានរបស់ក្រុមហ៊ុន OCIC

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ៨ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៣៥១..អនក្រ..បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ទោ **ឯក ចិន្តា** អត្តលេខ ០២១៦៦ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ... ឆ្នាំ២០១១

សារាចរណែនាំ

ស្ដីពី

ការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យ

អនុលោមតាមផ្នែកទី២ ស្ដីពីពន្ធលើអចលនទ្រព្យ នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ និងប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្ដីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីវិធាន និងនីតិវិធីនៃការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យ ដូចខាងក្រោម ៖

I- អចលនទ្រព្យដែលត្រូវជាប់ពន្ធ ៖

អចលនទ្រព្យដែលស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។ ពន្ធនេះត្រូវប្រមូលចំពោះអចលនទ្រព្យដែលមានតម្លៃលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល ។

ក្នុងដំណាក់កាលដំបូង ពន្ធលើអចលនទ្រព្យត្រូវបានអនុវត្តចំពោះតែអចលនទ្រព្យដែលស្ថិតក្នុងភូមិសាស្ត្ររដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ និងរដ្ឋបាលក្រុង នៃខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុណ្ណោះ ។

អ្នកជាប់ពន្ធ (ម្ចាស់អចលនទ្រព្យ) ដែលមានអចលនទ្រព្យមានតម្លៃលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល ត្រូវមានកាតព្វកិច្ចចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធនៅរដ្ឋបាលសារពើពន្ធ ក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ ។

ពន្ធលើអចលនទ្រព្យជាប្រភេទពន្ធស្វ័យប្រកាស ដោយម្ចាស់អចលនទ្រព្យត្រូវបំពេញព័ត៌មានអចលនទ្រព្យ ពាក្យស្នើសុំចុះបញ្ជីពន្ធលើអចលនទ្រព្យ លិខិតប្រកាសបង់ពន្ធលើអចលនទ្រព្យ និងគណនា ព្រមទាំងបង់ប្រាក់ពន្ធដោយខ្លួនឯង ។

ពន្ធលើអចលនទ្រព្យនេះត្រូវប្រមូលដោយរដ្ឋបាលសារពើពន្ធ និងបង់ចូលក្នុងគណនីទោលនៃរតនាគារជាតិ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ/ឃុំ/សង្កាត់) សម្រាប់ការអភិវឌ្ឍមូលដ្ឋាន ។

II- អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ ៖

អចលនទ្រព្យដែលត្រូវលើកលែងពន្ធ មានដូចខាងក្រោម ៖

១. អចលនទ្រព្យដែលជាដីធ្លីកសិកម្ម ។ "ដីធ្លីកសិកម្ម" គឺជាដីស្ថិតក្នុងតំបន់ ឬប្រភេទដីកសិកម្មដែលកំពុងបង្កបង្កើនផល មានដាំរុក្ខជាតិ ដីស្រែ ដីចំការ ដីដំណាំកសិ-ឧស្សាហកម្ម ដីកសិដ្ឋានចិញ្ចឹមសត្វ

វារីវប្បកម្ម ដីស្រែអំបិល ។

ក្នុងករណី អចលនទ្រព្យ ឬចំណែកណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្រៅតំបន់ ឬប្រភេទដីកសិកម្ម (តំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម) ដែលកំពុងបង្កបង្កើនផលកសិកម្មក្រោមរូបភាពដូចខាងក្រោម ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ៖

- ចិញ្ចឹមសត្វ ត្រូវមានលិខិតអនុញ្ញាតពីមន្ទីរកសិកម្ម
- វារីវប្បកម្ម ត្រូវមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល
- ក្រៅពីការចិញ្ចឹមសត្វ និងវារីវប្បកម្ម ត្រូវមានលិខិតបញ្ជាក់ពីខណ្ឌ/ស្រុក/ក្រុង

ឧទាហរណ៍១ ៖ លោក "គ" មានដីមួយកន្លែងស្ថិតក្នុងតំបន់ ឬប្រភេទដីលំនៅដ្ឋាន ដែលមានទំហំ ២.០០០ ម៉ែត្រក្រឡា ។ ដីនោះចំនួន ១.០០០ ម៉ែត្រក្រឡា កំពុងធ្វើស្រែដោយមានលិខិតបញ្ជាក់ពីខណ្ឌ/ស្រុក/ក្រុង ដីចំនួន ២០០ ម៉ែត្រក្រឡា សាងសង់លំនៅដ្ឋាន និងដីចំនួន ៨០០ ម៉ែត្រក្រឡា កំពុងចិញ្ចឹមត្រី ដោយមានការអនុញ្ញាតពីរដ្ឋបាលជលផល ។

ក្នុងករណីនេះ ដីចំនួន ២០០ ម៉ែត្រក្រឡា សាងសង់លំនៅដ្ឋាន និងសំណង់ ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។ ចំពោះដីចំនួន ១.០០០ ម៉ែត្រក្រឡា កំពុងធ្វើស្រែ និងដីចំនួន ៨០០ ម៉ែត្រក្រឡា កំពុងចិញ្ចឹមត្រីនិងសំណង់ដែលបម្រើផ្ទាល់ដល់ការងារចិញ្ចឹមត្រី ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។

ឧទាហរណ៍២ ៖ លោក "ខ" មានដីមួយកន្លែងស្ថិតក្នុងតំបន់ ឬប្រភេទដីកសិកម្ម ដែលមានទំហំ ២០.០០០ ម៉ែត្រក្រឡា ដីនោះចំនួន ១៤.០០០ ម៉ែត្រក្រឡា កំពុងធ្វើស្រែ ដីចំនួន ១.០០០ ម៉ែត្រក្រឡា សាងសង់សំណង់បម្រើផ្ទាល់ដល់ការងារកសិកម្ម និងដីចំនួន ៥.០០០ ម៉ែត្រក្រឡា សម្រាប់ធ្វើអាជីវកម្មផ្សេងៗ ។

ក្នុងករណីនេះ ដីចំនួន ១៤.០០០ ម៉ែត្រក្រឡា កំពុងធ្វើស្រែ និងដីចំនួន ១.០០០ ម៉ែត្រក្រឡា ដែលសំណង់នោះបម្រើផ្ទាល់ដល់ការងារកសិកម្ម ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។ ចំពោះដីចំនួន ៥.០០០ ម៉ែត្រក្រឡា សម្រាប់ធ្វើអាជីវកម្មផ្សេងៗ ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

ឧទាហរណ៍៣៖ លោក "គ" មានដីមួយកន្លែងជាប្រភេទដីលំនៅដ្ឋាន ស្ថិតនៅខេត្តកំពត ។ គាត់បានសាងសង់សំណង់មានកំពស់បីជាន់ ។ សំណង់ជាន់ផ្ទាល់ដី និងសំណង់ជាន់ទី១សម្រាប់ស្នាក់នៅ ។ សំណង់ជាន់ទី២ និងទី៣ គាត់កំពុងចិញ្ចឹមសត្វត្រចៀកកាំ ដោយមានការអនុញ្ញាតពីមន្ទីរ ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ក្នុងករណីនេះ ដី និងសំណង់ជាន់ផ្ទាល់ដី និងសំណង់ជាន់ទី១ ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។ ចំពោះសំណង់ជាន់ទី២ និងទី៣ ដែលគាត់កំពុងចិញ្ចឹមសត្វត្រចៀកកាំ ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។

២. អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល ដូចជា សាលារៀន មន្ទីរពេទ្យ ក្រសួង មន្ទីរ ស្ថាប័ន... ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌជាទ្រព្យសម្បត្តិរដ្ឋ ។ ក្នុងករណីអចលនទ្រព្យដែលបានកត់ត្រាជាទ្រព្យសកម្មធ្វើអាជីវកម្មរបស់សហគ្រាសសាធារណៈ ឬក្រុមហ៊ុនចម្រុះរដ្ឋ អចលនទ្រព្យនោះមិនត្រូវបានលើកលែងពន្ធលើអចលនទ្រព្យទេ ។ ចំពោះដីរដ្ឋដែលរាជរដ្ឋាភិបាលបានជួលឲ្យឯកជនសាងសង់សំណង់សម្រាប់ធ្វើអាជីវកម្ម ដីនោះត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ប៉ុន្តែសំណង់ត្រូវជាប់ពន្ធ ។

ឧទាហរណ៍៖ លោក "ឃ" បានជួលដីពីរដ្ឋរយៈពេល ៥០ឆ្នាំ ហើយបានសាងសង់សណ្ឋាគារមួយដើម្បីធ្វើអាជីវកម្ម ។

ក្នុងករណីនេះ ដីដែលគាត់ជួលពីរដ្ឋ ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។ ចំពោះសណ្ឋាគារដែលជាកម្មសិទ្ធិរបស់គាត់ ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

៣. អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់សហគមន៍ ឬបុគ្គលណាមួយ ដែល ៖

- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌ គ្មានចំណែកណាមួយនៃអចលនទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន ។

ការលើកលែងពន្ធលើអចលនទ្រព្យនេះមិនរាប់បញ្ចូលទេ ចំពោះ ៖

+ អចលនទ្រព្យដែលត្រូវបានជួល ឬផ្តល់ឱ្យបណ្តោះអាសន្ន សម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌
+ អចលនទ្រព្យជាកម្មសិទ្ធិរបស់អង្គការសាសនា ឬអង្គការសប្បុរសធម៌ ដែលបានជួល ឬផ្តល់ជាបណ្តោះអាសន្នឱ្យទៅសហគមន៍ ឬបុគ្គលណាមួយ ដែលប្រើប្រាស់អចលនទ្រព្យនោះក្រៅពីគោលដៅសាសនា និងសប្បុរសធម៌ ។

៤. អចលនទ្រព្យជាកម្មសិទ្ធិរបស់ ៖

- បេសកកម្មការទូត ឬកុងស៊ុលបរទេស
- អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ។

ការលើកលែងពន្ធនេះមិនរាប់បញ្ចូលទេ ចំពោះ ៖

+ អចលនទ្រព្យជាកម្មសិទ្ធិរបស់ឯកជន ហើយបានជួលទៅឱ្យបេសកកម្មការទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា
+ អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ដែលបានជួលទៅឱ្យអតិថិជន ។

៥. អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ស្ថានីយអយស្ម័យយាន រួមបញ្ចូលទាំងអគារ និងការិយាល័យដែលបម្រើផ្ទាល់ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ។

ឧទាហរណ៍ ៖ លោក "ក" បានធ្វើរោងចក្រអគ្គិសនីនៅលើដីមួយកន្លែង និងមានអគារមួយខ្នងនៅក្នុងបរិវេណដីនោះសម្រាប់បម្រើដល់ការងារផលិតកម្មអគ្គិសនី ។ រោងចក្រអគ្គិសនីខាងលើ ក៏មានការិយាល័យមួយចំនួនដែលស្ថិតនៅក្រៅបរិវេណដីខាងលើ ។

ក្នុងករណីនេះ ដី និងអគារសម្រាប់បម្រើដល់ការងារផលិតកម្មអគ្គិសនី ពុំជាប់ពន្ធលើអចលនទ្រព្យឡើយ ហើយការិយាល័យដែលស្ថិតនៅក្រៅបរិវេណដីខាងលើ ក៏ពុំត្រូវជាប់ពន្ធលើអចលនទ្រព្យ ដែរ ។

៦. ផ្ទះ អគារ និងសំណង់ផ្សេងៗ ដែលសាងសង់លើដីធ្លីកសិកម្មដែលបម្រើផ្ទាល់ និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម ។

៧. អចលនទ្រព្យដែលទទួលរងនូវការខូចខាតធ្ងន់ធ្ងរដោយករណីប្រធានសក្តិ ដែលជាបាតុភូត ឬជាព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបាន ដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុប្បកម្ម អគ្គីភ័យ ឬគ្រោះមហន្តរាយ ជាយថាហេតុ ។

ឧទាហរណ៍១ ៖ លោក "ក" មានដីមួយកន្លែងស្ថិតនៅតាមបណ្តោយមាត់ទន្លេមេគង្គក្នុងក្រុងកំពង់ចាម និងបានសង់ផ្ទះមួយខ្នងនៅក្នុងបរិវេណដីនោះសម្រាប់ស្នាក់នៅ ។ នៅខែសីហា និងកញ្ញានៃឆ្នាំនីមួយៗ ផ្ទះ និងដីរបស់គាត់ត្រូវរងនូវការលិចទឹកជារៀងរាល់ឆ្នាំ ។

ក្នុងករណីនេះ ដីនិងផ្ទះរបស់គាត់ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

ឧទាហរណ៍២ ៖ លោក "ខ" មានដីមួយកន្លែងដោយបានសាងសងរោងចក្រមួយ ដើម្បីផលិតនំនៅក្នុងបរិវេណដីនោះ ។ នៅឆ្នាំ២០១១ រោងចក្រគាត់ត្រូវភ្លើងឆេះអស់ ។ ក្នុងករណីនេះ ដីនិងរោងចក្ររបស់គាត់សម្រាប់ឆ្នាំ២០១១ ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។ សម្រាប់ឆ្នាំ២០១២ ដីគាត់ត្រូវជាប់ពន្ធលើអចលនទ្រព្យតាមធម្មតា ។

៨. ផ្ទះ អគារ ឬសំណង់ ដែលកំពុងត្រូវបានសាងសង់តិចជាង ៨០ (ប៉ែតសិប) ភាគរយ និងមិនទាន់បានប្រើប្រាស់ ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ បានន័យថា ផ្ទះ អគារ ឬសំណង់នោះត្រូវបានបំពេញលក្ខខណ្ឌពីរក្នុងពេលជាមួយគ្នាគឺ ទី១ កំពុងត្រូវបានសាងសង់តិចជាង ៨០ (ប៉ែតសិប) ភាគរយ និងទី២ មិនទាន់បានប្រើប្រាស់ ។ ប៉ុន្តែដីត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

ការប្រើប្រាស់ សំដៅដល់ការប្រើប្រាស់ផ្ទះ អគារ ឬសំណង់ សម្រាប់សកម្មភាពអាជីវកម្ម ឬស្នាក់នៅ ដោយមិនគិតថាការប្រើប្រាស់ ឬការស្នាក់នៅនោះ មានលក្ខណៈជាប់លាប់ ឬមួយដងមួយគ្រាឡើយ ។

៩. អចលនទ្រព្យដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។

ការលើកលែងពន្ធលើអចលនទ្រព្យនេះ មិនរាប់បញ្ចូលទេនូវសំណង់ដែលមិនបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម ឬសេវាកម្មដែលជាកម្មវត្ថុនៃតំបន់សេដ្ឋកិច្ចពិសេសនោះ ដូចជា ផ្ទះល្វែង ផ្ទះវីឡា ភោជនីយដ្ឋាន សណ្ឋាគារ កាស៊ីណូ កន្លែងលំហែកំសាន្តផ្សេងៗ ។

ឧទាហរណ៍ ៖ លោក "ក" បានទទួលសិទ្ធិគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសមួយ ក្នុងគោលបំណងដើម្បីសាងសង់រោងចក្រផលិតសំលៀកបំពាក់សម្រាប់នាំចេញ ។ ក្រោយមកលោក "ក" បានសាងសង់ផ្ទះល្វែង ភូមិគ្រឹះ សណ្ឋាគារសម្រាប់លក់ ឬជួល ដែលជាសកម្មភាពមិនបម្រើផ្ទាល់ដល់ការផលិតសំលៀកបំពាក់នាំចេញ ដែលជាកម្មវត្ថុនៃតំបន់សេដ្ឋកិច្ចពិសេសនោះទេ ដូចនេះ សំណង់ទាំងនោះត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

III- ចំណែកនៃអចលនទ្រព្យដែលមិនត្រូវគិតបញ្ចូលជាមូលដ្ឋានគិតពន្ធ ៖

ចំណែកនៃផ្ទះ អគារ ឬសំណង់ផ្សេងៗ មានដូចខាងក្រោមនេះ មិនត្រូវគិតបញ្ចូលជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យទេ ៖

១. ដំបូល ដែលគ្មានជញ្ជាំងជុំវិញ និងមិនធ្វើអាជីវកម្ម
២. សំយាបផ្ទះ ឬអគារ
៣ ពនហាលផ្ទះ ឬអគារ
៤. ឡៅតឿ
៥. ផ្ទះបាយ និងបន្ទប់ទឹកក្រៅផ្ទះ ឬអគារ
៦. កន្លែងដាក់យានជំនិះមិនធ្វើអាជីវកម្ម នៅក្រៅផ្ទះ ឬអគារ
៧. កន្លែងហាត់កីឡាមិនធ្វើអាជីវកម្មនៅក្រៅផ្ទះ ឬអគារ
៨. កន្លែងដាក់ម៉ាស៊ីនភ្លើងក្រៅផ្ទះ ឬអគារ
៩. អាងហែលទឹកមិនធ្វើអាជីវកម្មនៅក្រៅផ្ទះ ឬអគារ
១០. តូប (Kiosk)
១១. របង និងក្លោងទ្វារ
១២. ជណ្តើរប្រើប្រាស់រួមគ្នា
១៣. អាងស្តុកទឹក ឬប្រេងនៅក្រៅផ្ទះ ឬអគារ
១៤ អង់តែនទូរស័ព្ទ ឬទូរទស្សន៍

១៥. ប៉ុស្តិ៍យាម

១៦. ផ្លូវ ស្ពាន សួនច្បារ ក្រៅផ្ទះ ឬអគារ ។

IV- អត្រាពន្ធ និងមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ ៖

ពន្ធលើអចលនទ្រព្យ ត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០,១ (សូន្យក្បៀសមួយ) ភាគរយ លើមូលដ្ឋានគិតពន្ធ ។

មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ គឺ ៨០% (ប៉ែតសិបភាគរយ) នៃតម្លៃអចលនទ្រព្យសរុប (ទាំងតម្លៃដី និងតម្លៃសំណង់) តាមអាយុកាលសំណង់ និងប្រភេទសំណង់ (ឥដ្ឋបេតុង និងមិនមែនឥដ្ឋបេតុង) ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយកាត់បន្ថយនូវទឹកប្រាក់ ចំនួន ១០០.០០០.០០០ (មួយរយលាន) រៀល សម្រាប់អចលនទ្រព្យមួយ ។

"អាយុកាលសំណង់" ត្រូវគិតចាប់ពីឆ្នាំដែលសំណង់នោះសាងសង់រួចរាល់ ។

"សំណង់ឥដ្ឋបេតុង" សំដៅដល់សំណង់ដែលមានប្លង់សេ ។

V- ការគណនាប្រាក់ពន្ធ ៖

- ប្រាក់ពន្ធត្រូវគណនាតាមរូបមន្ត ដូចខាងក្រោម ៖
- មូលដ្ឋានគិតពន្ធ = (តម្លៃអចលនទ្រព្យ X ៨០%) - ១០០.០០០.០០០ រៀល
- ប្រាក់ពន្ធ = មូលដ្ឋានគិតពន្ធ X ០,១%

ឧទាហរណ៍ ៖ អចលនទ្រព្យមួយស្ថិតនៅសងខាងកំណាត់ផ្លូវសហព័ន្ធរុស្ស៊ី ចាប់ពីផ្លូវយោធពលខេមរភូមិន្ទ (២៧១) ដល់ផ្លូវចូលក្រសួងពាណិជ្ជកម្មថ្មី ។ អចលនទ្រព្យនោះ មានដីទំហំ ៤ម X ២០ម និងមានផ្ទះល្វែងកម្ពស់ ២ជាន់ (E_0,E_1,E_2) ដែលមានទំហំ ៤ម X ២០ម សាងសង់នៅឆ្នាំ២០០៥ និងមានតម្លៃទីផ្សារកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ក្នុងមួយម៉ែត្រក្រឡា ដូចខាងក្រោម ៖

- តម្លៃដី = ៧៥០ ដុល្លារ/ម៉ែត្រក្រឡា
- តម្លៃផ្ទះជាន់ផ្ទាល់ដី (E_0) = ២៥០ ដុល្លារ/ម៉ែត្រក្រឡា
- តម្លៃផ្ទះជាន់ទី១ (E_1) = ២០០ ដុល្លារ/ម៉ែត្រក្រឡា
- តម្លៃផ្ទះជាន់ទី២ (E_2) = ១៥០ ដុល្លារ/ម៉ែត្រក្រឡា

} អាយុកាលសំណង់ក្រោម១០ឆ្នាំ

ការគណនាតម្លៃអចលនទ្រព្យ ៖

- តម្លៃដី = ៤ម X ២០ម X៧៥០ ដុល្លារ = ៦០.០០០ ដុល្លារ
- តម្លៃផ្ទះជាន់ផ្ទាល់ដី (E_0) = ៤ម X ២០ម X ២៥០ ដុល្លារ = ២០.០០០ ដុល្លារ
- តម្លៃផ្ទះជាន់ទី១ (E_1) = ៤ម X ២០ម X ២០០ ដុល្លារ = ១៦.០០០ ដុល្លារ
- តម្លៃផ្ទះជាន់ទី២ (E_2) = ៤ម X ២០ម X ១៥០ ដុល្លារ = ១២.០០០ ដុល្លារ

តម្លៃអចលនទ្រព្យសរុប = **១០៨.០០០ ដុល្លារ**

តម្លៃសរុប ៨០% ជាប្រាក់រៀល = ១០៨.០០០ ដុល្លារ X ៨០% X ៤.០០០ រៀល
= ៣៤៥.៦០០.០០០ រៀល

មូលដ្ឋានគិតពន្ធ = (តម្លៃអចលនទ្រព្យ - ១០០.០០០.០០០ រៀល)
= (៣៤៥.៦០០.០០០ រៀល - ១០០.០០០.០០០ រៀល)
= ២៤៥.៦០០.០០០ រៀល

ដូចនេះ ប្រាក់ពន្ធត្រូវបង់ = ២៤៥.៦០០.០០០ រៀល X ០,១% = **២៤៥.៦០០ រៀល**
= ៦១,៤ ដុល្លារ

VI- វិធីវាស់វែងអចលនទ្រព្យ ៖

ម្ចាស់អចលនទ្រព្យត្រូវធ្វើការវាស់វែងរកទំហំជាក់ស្តែងនៃផ្ទៃក្រឡាដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ដូចខាងក្រោម ៖

១. ចំពោះដី ត្រូវយកចំណុចកណ្តាលនៃព្រំរបង ឬព្រំដី ជាគោល ។

២ ចំពោះផ្ទះ អគារ និងសំណង់ផ្សេងៗ ត្រូវយកចំណុចកណ្តាលនៃជញ្ជាំងផ្ទះ អគារ និងសំណង់ផ្សេងៗ ជាគោល ។ ក្នុងករណីសំណង់គ្មានជញ្ជាំងដែលត្រូវជាប់ពន្ធលើអចលនទ្រព្យ ត្រូវយកចុងដំបូលជាគោល ឧទាហរណ៍ ស្ថានីយ៍ប្រេង រោងនីយដ្ឋាន កន្លែងលក់ ឬលាងយានយន្ត ។

VII- សិទ្ធិស្របច្បាប់នៃអចលនទ្រព្យ ៖

បុគ្គលដែលកាន់កាប់ ឬទទួលផលប្រយោជន៍ពីអចលនទ្រព្យរបស់រដ្ឋដោយពុំស្របច្បាប់ ឬអចលនទ្រព្យមានទំនាស់ ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើអចលនទ្រព្យ ដូចអចលនទ្រព្យដែលបាន និងកំពុងកាន់កាប់ស្របច្បាប់ដែរ ។

ការចុះបញ្ជី ការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធលើអចលនទ្រព្យ មិនមែនជាលក្ខខណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់របស់ម្ចាស់អចលនទ្រព្យទេ ។

VIII- ការទទួលទម្រង់លិខិតពន្ធលើអចលនទ្រព្យ ៖

ម្ចាស់អចលនទ្រព្យអាចទទួលយកទម្រង់ព័ត៌មានអចលនទ្រព្យ ពាក្យស្នើសុំចុះបញ្ជីពន្ធលើអចលនទ្រព្យ និងលិខិតប្រកាសពន្ធលើអចលនទ្រព្យ ពីឃុំ/សង្កាត់ ឬសាខាពន្ធដារខេត្ត/ខណ្ឌ ឬអាចទាញយកពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ (www.tax.gov.kh) ។

IX- ការបំពេញទម្រង់ព័ត៌មានអចលនទ្រព្យ ៖

ម្ចាស់អចលនទ្រព្យមានកាតព្វកិច្ចបំពេញទម្រង់ព័ត៌មានអចលនទ្រព្យ ទោះបីជាអចលនទ្រព្យនោះជាប់ពន្ធ ឬមិនជាប់ពន្ធក្តី ។ អចលនទ្រព្យដែលត្រូវលើកលែងពន្ធ ពុំមានកាតព្វកិច្ចបំពេញព័ត៌មានអចលនទ្រព្យជូនសាខាពន្ធដារខេត្ត/ខណ្ឌ លើកលែងតែអចលនទ្រព្យដែលស្ថិតនៅក្រៅតំបន់ ឬប្រភេទដីកសិកម្ម (តំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម) ដូចមានចែងក្នុងចំណុច II.1 (អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ ដែលស្ថិតនៅក្រៅតំបន់ ឬប្រភេទដីកសិកម្ម) ត្រូវបំពេញព័ត៌មានអចលនទ្រព្យ ។

ម្ចាសអចលនទ្រព្យត្រូវយកទម្រង់ព័ត៌មានអចលនទ្រព្យមកប្រគល់ជូនក្រុមការងារឃុំ/សង្កាត់ ឬយកមកប្រគល់ជូនសាខាពន្ធដារខេត្ត/ខណ្ឌ ដែលអចលនទ្រព្យនោះស្ថិតនៅ ។ សេចក្តីណែនាំស្តីពីការបំពេញទម្រង់ព័ត៌មានអចលនទ្រព្យ មានបញ្ជាក់ជូននៅខាងខ្នងនៃទម្រង់ព័ត៌មានអចលនទ្រព្យ ។

X- ការចុះបញ្ជីអចលនទ្រព្យ ៖

១. អ្នកជាប់ពន្ធដែលមានអចលនទ្រព្យមានតម្លៃលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល ត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនិមួយៗ ។ អ្នកជាបពន្ធដែលមានអចលនទ្រព្យមានតម្លៃតិចជាង ឬស្មើនឹង ១០០.០០០.០០០ (មួយរយលាន) រៀល ពុំមានកាតព្វកិច្ចចុះបញ្ជីឡើយ ។

២ អចលនទ្រព្យមួយត្រូវចុះបញ្ជីតែម្តងគត់ និងត្រូវទទួលបានលេខអត្តសញ្ញាណកម្មអចលនទ្រព្យមួយដែលចេញដោយរដ្ឋបាលសារពើពន្ធ ។ អចលនទ្រព្យមួយសំដៅដល់អចលនទ្រព្យដែលមានឯកសារ

សម្គាល់អចលនទ្រព្យមួយ ដូចជា ៖ បណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ ដោយអាជ្ញាធរឃុំ/សង្កាត់ ឡើងទៅ ។

៣. ការចុះបញ្ជីអចលនទ្រព្យ អ្នកជាប់ពន្ធត្រូវបំពេញទម្រង់ចុះបញ្ជីអចលនទ្រព្យដែលបានផ្តល់ជូនដោយឥតគិតថ្លៃ និងភ្ជាប់មកជាមួយនូវឯកសារថតចម្លង ដូចខាងក្រោម ៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ
- បណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ/សង្កាត់ឡើងទៅ ។ ករណីអចលនទ្រព្យត្រូវបានទិញបង់រំលស់ ម្ចាស់អចលនទ្រព្យត្រូវភ្ជាប់មកជាមួយនូវឯកសារកិច្ចសន្យារវាងអ្នកទិញ និងអ្នកលក់ ។

៤. អ្នកជាប់ពន្ធត្រូវផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ក្នុងករណីដូចខាងក្រោម ៖

ក. មូលដ្ឋានគិតពន្ធ ត្រូវបានប្រែប្រួល ដូចជា

- ដីត្រូវបានយកទៅសាងសង់ផ្ទះ អគារ និង/ឬសំណង់ផ្សេងៗ
- ផ្ទះ អគារ និងសំណង់ផ្សេងៗ ត្រូវបានសាងសង់បន្ថែម ឬបន្ថយ ឬរំលាយចោល

ខ. អចលនទ្រព្យត្រូវបានផ្លាស់ប្តូរកម្មសិទ្ធិករ អ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយ

៥. ក្នុងករណីអចលនទ្រព្យត្រូវបំបែកលក់ ឬឱ្យជាអំណោយ ។

ឧទាហរណ៍ ៖ អ្នកជាប់ពន្ធមានដីមួយកន្លែង ហើយត្រូវបានបំបែកជាឡូតិ៍លក់ អ្នកជាប់ពន្ធត្រូវផ្តល់ព័ត៌មានដល់រដ្ឋបាលសារពើពន្ធ ដើម្បីទទួលលេខអត្តសញ្ញាណកម្មថ្មី ។

XI- ការដាក់លិខិតប្រកាស និងការបង់ពន្ធ ៖

១. ម្ចាស់អចលនទ្រព្យមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ ចាប់ពីថ្ងៃទី០១ ខែមករា រហូត ដល់ថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ ។

២. ម្ចាស់អចលនទ្រព្យត្រូវដាក់លិខិតប្រកាសចំនួនពីរច្បាប់ (មួយច្បាប់សម្រាប់រដ្ឋបាលសារពើពន្ធ និងមួយច្បាប់ទៀត សម្រាប់ម្ចាស់អចលនទ្រព្យ) និងគណនាប្រាក់ពន្ធ ដោយផ្អែកលើតារាងតម្លៃអចលនទ្រព្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ម្ចាស់អចលនទ្រព្យអាចធ្វើការបង់ប្រាក់ពន្ធតាមប្រព័ន្ធធនាគារ តាមការណែនាំរបស់សាខាពន្ធដារខេត្ត/ខណ្ឌ ឬបង់ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធដែលអចលនទ្រព្យនោះស្ថិតនៅ ។

៣. ប្រសិនបើម្ចាស់អចលនទ្រព្យមានអចលនទ្រព្យច្រើន ហើយស្ថិតនៅភូមិសាស្ត្ររដ្ឋបាលខុសគ្នា ម្ចាស់អចលនទ្រព្យត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធដាច់ដោយឡែកពីគ្នា ទៅតាមភូមិសាស្ត្រដែលអចលនទ្រព្យស្ថិតនៅ ។

៤. សម្រាប់ការបង់ពន្ធតាមប្រព័ន្ធធនាគារ ម្ចាស់អចលនទ្រព្យត្រូវយកលិខិតប្រកាសជូនរដ្ឋបាលសារពើពន្ធ ពិនិត្យជាមុនសិន មុននឹងបង់ប្រាក់ពន្ធនៅធនាគារ ។ បន្ទាប់មក ម្ចាស់អចលនទ្រព្យត្រូវយកបង្កាន់ដៃទទួលប្រាក់របស់ធនាគារភ្ជាប់ជាមួយលិខិតប្រកាសដាក់ជូនរដ្ឋបាលសារពើពន្ធវិញ ។ ក្នុងករណី

ម្ចាស់អចលនទ្រព្យយល់ថា ការបំពេញលិខិតប្រកាសរបស់ខ្លួនពិតជាត្រឹមត្រូវ ម្ចាស់អចលនទ្រព្យអាចបង់ប្រាក់ពន្ធនៅធនាគារតែម្តង ហើយត្រូវដាក់លិខិតប្រកាសជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាបមកជាមួយនូវបង្កាន់ដៃទទួលប្រាក់របស់ធនាគារ ។ ក្រោយពីបានទទួលលិខិតប្រកាស និងបង្កាន់ដៃទទួលប្រាក់របស់ធនាគារ រដ្ឋបាលសារពើពន្ធត្រូវចេញបង្កាន់ដៃដែលបញ្ជាក់ថា បានបង់ប្រាក់ពន្ធរួចហើយ ។

៥. ក្នុងករណីមិនយល់ច្បាស់អំពីវិធីគណនា ឬការបំពេញលិខិតប្រកាស អ្នកជាប់ពន្ធអាចទាក់ទងមកសាខាពន្ធដារខេត្ត/ខណ្ឌ ដែលអចលនទ្រព្យស្ថិតនៅ ដើម្បីទទួលការណែនាំ ។

៦. ក្នុងករណីអចលនទ្រព្យណាមួយត្រូវបានលក់ ឬផ្ទេរ ឬផ្តល់ជាអំណោយដោយម្ចាស់អចលនទ្រព្យ ប្រសិនបើអចលនទ្រព្យនោះពុំទាន់បានបង់ពន្ធនៅឡើយ រាល់បំណុល និងកាតព្វកិច្ចពន្ធលើអចលនទ្រព្យ គឺបុគ្គលដែលជាអ្នកទទួលប្រយោជន៍ចុងក្រោយ ជាអ្នកទទួលបន្ទុក ។

XII- សិទ្ធិនៃការត្រួតពិនិត្យ និងទោសទណ្ឌ ៖

១ ជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែតុលា នៃឆ្នាំជាប់ពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិត្រួតពិនិត្យលើមូលដ្ឋានគិតពន្ធ និងការបង់ពន្ធរបស់អ្នកជាប់ពន្ធ ។ ការត្រួតពិនិត្យនេះផ្តោតសំខាន់ទៅលើអ្នកជាប់ពន្ធដែលមានអចលនទ្រព្យមានតម្លៃលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល ដែល ៖

- មិនបានមកចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ
- មិនបានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និងបង់ពន្ធ
- បង់ពន្ធខ្វះដោយប្រកាសមិនអស់នូវអចលនទ្រព្យដែលខ្លួនមាន ឬប្រកាសប្រាក់ពន្ធទាបជាងប្រាក់ពន្ធត្រូវបង់
- បង់ពន្ធយឺតយ៉ាវមិនតាមកាលកំណត់ ។

២. ក្នុងករណីមិនបានចុះបញ្ជី មិនបានដាក់លិខិតប្រកាសពន្ធ បង់ពន្ធខ្វះ ឬបង់ពន្ធយឺត អ្នកជាប់ពន្ធដែលជាម្ចាស់អចលនទ្រព្យ ត្រូវរងទោសទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ ។

XIII- ទំនាក់ទំនងរវាងពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនប្រើប្រាស់ ៖

ដីជាកម្មវត្ថុត្រូវជាប់ពន្ធលើអចលនទ្រព្យដែលបានបង់ពន្ធរួចហើយ ដីនោះពុំត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ទៀតទេ ដោយអនុវត្តគិតចាប់ពីឆ្នាំ២០១១ ដែលដាក់ឱ្យអនុវត្តពន្ធលើអចលនទ្រព្យនេះ ។ សម្រាប់ដីធ្លីមិនបានប្រើប្រាស់ និងមិនទាន់បានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់មុនឆ្នាំ២០១១ ដីនោះនៅតែជាប់បំណុលពន្ធលើដីធ្លីមិនបានប្រើប្រាស់នៃឆ្នាំជាប់ពន្ធកន្លងមក ។

ចំពោះដីដែលមានតម្លៃស្មើ ឬតិចជាង ១០០.០០០.០០០ រៀល ដែលមិនជាប់ពន្ធអចលនទ្រព្យ ដីនោះនៅតែជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

XIV- នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា ៖

តាមមាត្រា១១៨ ដល់ មាត្រា១២៤ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងករណីដែលម្ចាស់អចលនទ្រព្យ មិនពេញចិត្តទៅនឹងសេចក្តីសម្រេចផ្សេងៗ ឬអំពើខុសឆ្គងណាមួយរបស់រដ្ឋបាលសារពើពន្ធ ម្ចាស់អចលនទ្រព្យមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ។ នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាសង្ខេប មានដូចខាងក្រោម ៖

- ជាដំបូង ម្ចាស់អចលនទ្រព្យត្រូវដោះស្រាយបញ្ហាជាមួយមន្ត្រីពន្ធដារដែលទទួលបន្ទុកកិច្ចការនោះ ។ ប្រសិនបើម្ចាស់អចលនទ្រព្យនៅតែមិនពេញចិត្ត ឬយល់ថា ពិបាកលើកបញ្ហាមកពិភាក្សាជាមួយមន្ត្រី

ទទួលបន្ទុកសូមដាក់ពាក្យតវ៉ាជូនមកប្រធានសាខាពន្ធដារខេត្ត/ខណ្ឌ ដែលអចលនទ្រព្យនោះស្ថិតនៅ ។

- ប្រសិនបើម្ចាស់អចលនទ្រព្យនៅតែមិនពេញចិត្ត ចំពោះការដោះស្រាយបណ្តឹងតវ៉ារបស់សាខាពន្ធដារខេត្ត/ខណ្ឌ សូមដាក់ពាក្យបណ្តឹងតវ៉ាជូនមកអគ្គនាយកដ្ឋានពន្ធដារ ។
- ប្រសិនបើម្ចាស់អចលនទ្រព្យនៅតែមិនពេញចិត្ត ចំពោះការដោះស្រាយបណ្តឹងតវ៉ារបស់អគ្គនាយកដ្ឋានពន្ធដារ សូមដាក់ពាក្យបណ្តឹងតវ៉ាជូនមកគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ ។
- ប្រសិនបើម្ចាស់អចលនទ្រព្យនៅតែមិនពេញចិត្ត ចំពោះការដោះស្រាយបណ្តឹងតវ៉ារបស់គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ សូមដាក់ពាក្យបណ្តឹងតវ៉ាជូនទៅតុលាការ ។

ទទួលបានសារាចរណែនាំនេះ អគ្គនាយកដ្ឋានពន្ធដារ សាលារាជធានី/ខេត្ត សាខាពន្ធដារខេត្ត/ខណ្ឌ ក្រុមការងារឃុំ/សង្កាត់ និងម្ចាស់អចលនទ្រព្យទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តសារាចរណែនាំស្តីពីការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

<u>ចម្លងជូន</u> ៖

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
គ្រប់ក្រសួង ស្ថាប័ន
គ្រប់សាលារាជធានី/ខេត្ត "ដើម្បីជូនជ្រាបជាព័ត៌មាន"
គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីមុខការ"
ឯកសារ-កាលប្បវត្តិ

p

p

p

បោះពុម្ពនៅអគ្គនាយកដ្ឋាន

រាជកិច្ច និង សេវាកុំព្យូទ័រ

នៃ ទីស្តីការគណៈរដ្ឋមន្ត្រី

p